[ERN 00396488-00396489]

ការជម្លៀសប្រជាជនចេញពីទីក្រុង និងផលវិបាកទាំងឡាយដែលកើតឡើងភ្លាមៗ រួមមានការប្ដូរទីលំនៅប្រជាជនទាំងអស់ឲ្យទៅរស់នៅក្នុងជនបទ ការកាប់សម្លាប់អតីតគូបដិបក្ខ កំណែទម្រង់ ឬការលុបបំបាត់អ្វីៗទាំងអស់ដែលត្រូវបានចាត់ទុកអាចកើតមានអរិភាព  ជាឧទាហរណ៍ស្ទើតែល្អឥតខ្ចោះនៃអ្វីដែលបានកើតឡើងក្នុងរបបបីឆ្នាំ ប្រាំខែ ម្ភៃថ្ងៃ។

ប្រជាជនភាគច្រើននៅក្នុងទីក្រុង មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ដោយហេតុថាពួកគេ និងពិភពលោកខាងក្រៅ បង្ហាញការយកចិត្តទុកដាក់តិចតួចប៉ុណ្ណោះចំពោះពួកខ្មែរក្រហម។ អ្វីដែលបានកើតឡើងក្នុងពាក់កណ្ដាលខែ មេសា ឆ្នាំ១៩៧៥ ជាផ្លែផ្កានៃគោលនយោបាយដែលបានបង្កើតឡើងចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៦០ និងមានប្រភពតាំងពីយូរយាណាស់មកហើយ។

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 10-Aug-2018, 08:40
CMS/CFO: Ly Bunloung



Translated: [00396488-00396489]; [00396491]; [00396530]; [00396497-00396499]; [00396713-00396714]; [00396501-00396502]; [00396503-00396504]; [00396508-00396509]; [00396425]; [00396536]; [00396513]; [00396514]; [00396577-00396578]; [00396721]; [00396514-00396516]; [00396552-00396553]; [00396528]; [00396529]; [00396530]; [00396554]; [00396555]; [00396556]; [00396560]

[ERN 00396491]

លក្ខណៈសំខាន់ផ្សេងៗទៀតនៃការជម្លៀស រួមមានការដកហូតជាប្រព័ន្ធនៃកម្មសិទ្ធិរបស់អ្នកមាន និងអ្នកមធ្យម ការសរសេរម្តងហើយម្តងទៀតនៃប្រវត្តិរូបសង្ខេបផ្ទាល់ខ្លួន ដើម្បីកំណត់អត្តសញ្ញាសត្រូវ ការប្រហារជីវិតដោយគ្មានការជំនុំជម្រះក្តី ភាពស្ទើតែមិនមានការប្រឆាំងពីសំណាក់ប្រជាជនរាប់លាននាក់ ការបណ្តេញចេញពីផ្ទះ និងដំណើរហាក់ដូចសត្វចៀមដែលត្រូវបានយកទៅសត្តឃាត គឺជាការដកពិសោធន៍បឋមដែលរបបនោះយកមកអនុវត្ត។

កាលពីថ្ងៃទី ៤ ការវាយប្រហាររបស់វៀតណាមបានផ្អាកមួយរយៈ។ អ្នកការទូតនានា បានត្រលប់មកស្ថានទូតរបស់ពួកគេរៀងៗខ្លួន ខណៈដែលសម្តេច សីហនុ និងលោក ប៉ែន នុត ត្រូវបានជូនត្រលប់មកពីព្រំដែនថៃវិញ។ បន្ទាប់មក ការវាយលុក បានចាប់ផ្តើមឡើងវិញ។ នៅល្ងាចបន្ទាប់ ប៉ុល ពត បានជួបសម្តេច សីហនុ នៅនិវេសដ្ឋានអតីតអគ្គទេសាភិបាលបារាំង បច្ចុប្បន្ន ត្រូវបានហៅថាផ្ទះលេខ១។ ពេលនោះ ប៉ុល ពត បានស្នើឲ្យសម្តេច សីហនុ យាងទៅកាន់អង្គការសហប្រជាជាតិ ដើម្បីអំពាវនាវឲ្យក្រុមប្រឹក្សាសន្តិសុខការពារបុព្វហេតុកម្ពុជា។ កិច្ចប្រជុំដែលបានបញ្ចប់ដោយពិធីលៀងសាយភោជន៍ មានរយៈពេលបួនម៉ោង។ វាជាលើកដំបូងដែលសម្តេច សីហនុ បានឃើញយ៉ាងច្បាស់នូវបុគ្គលិកលក្ខណៈដែលមានភាពទាក់ទាញរបស់ប៉ុលពត ហើយសម្តេច សីហនុ មានការចាប់អារម្មណ៍។ សម្តេច សីហនុ បានសរសេរនៅរយៈកាលក្រោយថា "គាត់រង់ចាំខ្ញុំ ដោយទឹកមុខញញឹម នៅក្រៅទ្វារធំនៃនិវេសដ្ឋាន។" "គាត់បានក្រាបបង្គំខ្ញុំតាមប្រពៃណី ដោយលុតក្រាបបន្តិច ដូចនៅក្នុងសង្គមចាស់ដែរ...។ បន្ទាប់មក អ្នកបម្រើដែលមានសម្លៀកបំពាក់ដ៏ស្អាតបាត បានចាក់តែឲ្យយើង និងរៀបចំនំដ៏ឆ្ងាញ់ពិសារ និងទឹកក្រូចស្រស់។" សម្តេច សីហនុ កត់សម្គាល់ថាមេដឹកនាំខ្មែរក្រហមបានប្រើរាជស័ព្ទ និងនិយាយដោយ "ងាយស្រួល និងស្ទាត់ជំនាញ...គាត់មានអំណោយទាន...និង "មានសម្តីផ្អែម និងពូកែបញ្ចុះបញ្ចូល។" ប៉ុល ពត បានអះអាងថ្វាយសម្តេច សីហនុ ថាវៀតណាម បានដើរចូលក្នុងអន្ទាក់ហើយ។ គាត់បាននិយាយថា ទាហានខ្មែរក្រហម មានចេតនាបញ្ឆោតឲ្យពួកគេចូលជ្រៅក្នុងទឹកដីកម្ពុជា។ គាត់បានពន្យល់ថាវាជាកលល្បិចដើម្បីឲ្យពួកគេគិតថាយើងមានកម្លាំងយោធាខ្សោយ។ "នៅពេលដែល



Translated: [00396488-00396489]; [00396491]; [00396530]; [00396497-00396499]; [00396713-00396714]; [00396501-00396502]; [00396503-00396504]; [00396508-00396509]; [00396425]; [00396536]; [00396513]; [00396514]; [00396577-00396578]; [00396721]; [00396514-00396516]; [00396552-00396553]; [00396528]; [00396529]; [00396530]; [00396554]; [00396555]; [00396556]; [00396560]

ពួកគេចូលមកក្នុងព្រំដែនរបស់យើង យើងនឹងជញ្ជាំពួកគេជាឲ្យមត់...ឲ្យពួកគេលង់ស្លាប់ដោយការទប់ទល់ប្រឆាំងរបស់ប្រជាជនរហូតដល់ពួកគេរលាយដូចអំបិលត្រូវទឹក។" គាត់បាននិយាយតាមវិទ្យុក្នុងមុននេះនៅថ្ងៃតែមួយ ដោយចោទវៀតណាម ថា"បានប៉ុងប៉ងលុបបំបាត់ជាតិសាសន៍កម្ពុជា" និងព្យាករណ៍ថាពួកគេនឹងវិនាសដោយ "ការផ្ទុះកំហឹងឈឺចាប់របស់ជាតិ"។

សម្តេច សីហនុ ចាត់ទុកការលើកឡើងនេះគ្រាន់តែជាការភូតកហុកជាធម្មតានៅក្នុងសេចក្តីថ្លែងការណ៍វិសាមញ្ញជាច្រើនរបស់ខ្មែរក្រហម។ ប៉ុន្តែពេលនោះ គាត់ហាក់ដូចជាយល់ខុស។

ប៉ុល ពត បានដឹងច្បាស់ថាខ្សែក្រវ៉ាត់ការពារសមរភូមិ បានបរាជ័យហើយ។ ជម្រើសចុងក្រោយតែមួយគត់គឺការច្បាំងដោយចល័តទ័ព។ ប៉ុន្តែ គាត់នៅជឿជាក់ថានៅពេលបោះបង់ទីក្រុងភ្នំពេញ ហើយវៀតណាមព្យាយាមកាន់កាប់ដែនដីខាងក្នុងនោះ វានឹងត្រូវរាំរាំង និងក្លាយជាគោលដៅងាយស្រួលសម្រាប់កងទ័ពព្រៃខ្មែរក្រហម។ គាត់ប្រកាសថាការវាយលុករបស់វៀតណាម "នឹងមានរយៈពេលខ្លីប៉ុណ្ណោះ" ។ មេដឹកនាំមួយរូបទៀត មានទស្សនៈដូចគ្នា។ លោក ខៀវ សំផន គិតថា "យើងនឹងចាកចេញភ្នំពេញបណ្តោះអាសន្នតែប៉ុណ្ណោះ ហើយយើងត្រូវត្រលប់មកវិញ។" នៅក្រសួងការបរទេស លោក សូ ហុង បានប្រាប់សហការីគាត់ថាវានឹង "ចប់សព្វគ្រប់ក្នុងរយៈពេលពីរបីសប្តាហ៍។" ការលើកឡើងនោះ គ្រាន់ជាទស្សន៍ទាយស្មានៗតែប៉ុណ្ណោះ ប៉ុន្តែវាបានឆ្លុះបញ្ចាំងអំពីការជឿជាក់ជាទូទៅ ដូចការលើកឡើងរបស់លោក អ៊ិន សូភាព ថា "យោធា បានគ្រប់គ្រងស្ថានការណ៍"។

លោក ខៀវសំផន និង សុន សេន បានអមព្រះរាជដំណើរយាងចាកចេញរបស់សម្តេច សីហនុ នៅឯអាកាសយានដ្ឋាន ដោយមានវត្តមានអគ្គរដ្ឋទូតចិន និងអគ្គរដ្ឋយូហ្គោស្លាវីផងដែរ។ មិនយូរប៉ុន្មាន អគ្គរដ្ឋទូតទាំងពីររូប ក៏នឹងចាកចេញផងដែរ។

សុន សេន បានចាកចេញពីទីក្រុងនៅពេលល្ងាចនោះ ដោយធ្វើដំណើរដោយសម្ងាត់ឆ្លងកាត់ខ្សែរត្រៀមវៀតណាមទៅកាន់កំពង់ចាម ដើម្បីប្រមូលកងពលខ្មែរក្រហមសេសសល់នៅសមរភូមិបូព៌ា។ ប៉ុល ពត, នួន ជា និងខៀវ សំផន ដោយរួមដំណើរដោយអង្គរក្សធ្វើដំណើរតាមរថយន្តហ្ស៊ីបចំនួនបីបួនគ្រឿង បានចេញដំណើរតាំងពីព្រលឹមស្រាងនៅថ្ងៃបន្ទាប់ ថ្ងៃអាទិត្យ ទី ៧ ខែ មករា ឆ្ពោះទៅពោធិ៍សាត់ នៅជិតទន្លេសាប ដែល



Translated: [00396488-00396489]; [00396491]; [00396530]; [00396497-00396499]; [00396713-00396714]; [00396501-00396502]; [00396503-00396504]; [00396508-00396509]; [00396425]; [00396536]; [00396513]; [00396514]; [00396577-00396578]; [00396721]; [00396514-00396516]; [00396552-00396553]; [00396528]; [00396529]; [00396530]; [00396554]; [00396555]; [00396556]; [00396560]

នៅពាក់កណ្តាលផ្លូវពីភ្នំពេញ ទៅបាត់ដំបង។ ប៉ុល ពត ធ្វើដំណើរតាមរថយន្តខ្ពស់ Chevrolete ងាយស្រួលធ្វើដំណើរតាមផ្លូវគ្រលុក ជាងរថយន្ត Mercedes របស់គូកនគាត់។ អៀង សារីធ្វើដំណើរតាមរថភ្លើងពិសេសទៅបាត់ដំបង ជាមួយបុគ្គលិកក្រសួងការបរទេសរាប់រយនាក់ជាមួយនឹងបណ្ណសារក្រសួង ដែលត្រូវបានវេចខ្ចប់យ៉ាងប្រញាប់ប្រញាល់មួយថ្ងៃមុន។

ដូច្នេះ នៅពាក់កណ្តាលព្រឹកថ្ងៃអាទិត្យ មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ បានរត់ចោល និងបោះបង់ចោលទីក្រុងដោយសម្ងាត់ដោយខ្លួនឯង។ កម្មករ និងទាហានចំនួន ៤០.០០០នាក់ និងកងយោធា ដែលមានមូលដ្ឋានក្នុងទីក្រុង ត្រូវបានទុកនៅចោល ដោយគ្មានមេដឹកនាំការពារពួកគេឡើយ។

ភាពវឹកវរ និងភាពគ្មានរបៀបរៀបរយក្នុងប៉ុន្មានថ្ងៃចុងក្រោយ ដែលជាភាពអសមត្ថភាពទាំងស្រុងរបស់រដ្ឋាភិបាលប៉ុល ពត, អវត្តមាននៃផែនការសមស្របសម្រាប់ការទប់ទល់ ការមិនព្រមប្រឈមមុខនឹងការពិតអំពីការដួលរលំទីក្រុងភ្នំពេញនៅពេលខ្លីខាងមុខ និងការខកខានមិនបានជម្លៀសអ្នករងរបួស បានបង្ហាញពីការអស់លទ្ធភាពរបស់របបនោះ។ ក្នុងកាលៈទេសៈណាក៏ដោយ វាវិនាសអន្តរាយ ដោយសារមិនដឹងពីរបៀបគ្រប់គ្រង។

គោលនយោបាយរបស់ខ្មែរក្រហម រហូតដល់វេលាចុងក្រោយ នៅតែស្របទៅនឹងអ្វីៗទាំងអស់ដែលបានអនុវត្តតាំងពីពេលមុន។ ការងារអាទិភាព រួមមានការរក្សាសុវត្ថិភាពសម្តេច សីហនុ និងការការពារប៉ុល ពត និងមេដឹកនាំដទៃទៀត ជាការអនុវត្តជាក់ស្តែងនូវគោលការណ៍លើកឡើងដោយនួន ជា កាលពីប៉ុន្មានខែមុនថា “ប្រសិនបើយើងបាត់បង់សមាជិក ប៉ុន្តែយើងនៅរក្សាបានអ្នកដឹកនាំ យើងអាចបន្តយកឈ្នះ។” ទស្សនៈដែលថាប្រជាជនសាមញ្ញ អាចមានចំនួនកើនឡើងវិញបាន ត្រូវបានខ្មែរក្រហមអនុវត្តចាប់តាំងពីពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញក្នុងខែ មេសា ឆ្នាំ ១៩៧៥។ ភាពខ្វះការយកចិត្តទុកដាក់ពីការបាត់បង់ជីវិត និងការចំណាយខ្ជះខ្ជាយធនធានសំខាន់ៗ នៅតែអនុវត្តដូចក្នុងរយៈកាលបីឆ្នាំកន្លះកន្លងមក។

**ជើងទំព័រ៖**

៣៩៦-៧ ***ប៉ុល ពត បានជួបសម្តេច សីហនុ...ទឹកម៉ាស៊ីន៖*** *សីហនុ អ្នកទោស,* ទំព័រ ៣១៦-២០។



Translated: [00396488-00396489]; [00396491]; [00396530]; [00396497-00396499]; [00396713-00396714]; [00396501-00396502]; [00396503-00396504]; [00396508-00396509]; [00396425]; [00396536]; [00396513]; [00396514]; [00396577-00396578]; [00396721]; [00396514-00396516]; [00396552-00396553]; [00396528]; [00396529]; [00396530]; [00396554]; [00396555]; [00396556]; [00396560]

៣៩៧ *គាត់បាននិយាយ...រយៈពេលខ្លី៖ ប៉ុលពត*, សេចក្ដីអំពាវនាវទៅកាន់ប្រជាជនកម្ពុជា ផ្សាយនៅព្រលឹមថ្ងៃទី ៥ ខែ មករា ម៉ោងក្នុងប្រទេស BBC SWB FE6009/A3/1-3។ *ចិន ទទួលបានព័ត៌មានផ្សេង៖* Yun Shui, Diplomats ទំព័រ ៤៩៩-៥០១។

៣៩៨ *សុន សេន បានចាកចេញពីទីក្រុង៖* កិច្ចសម្ភាសន៍ជាមួយ ភី ភួន។ *ចេញដំណើរពេលព្រលឹមស្រាងៗ៖ ដូចជើងទំព័រខាងលើ,* កិច្ចសម្ភាសន៍ជាមួយខៀវ សំផន។ លោក David Chandler ដែលផ្អែកលើកំណត់ប្រវត្តិរបស់ អ៊ី ផាន់ដារ៉ា ពិពណ៌នាអំពីឧទ្ធម្ភាគចក្រចំនួនពីរគ្រឿងដែលបានហោះរំលងភ្នំពេញនៅព្រឹកនោះ "ដឹកប៉ុល ពត និងសហការីជិតស្និទ្ធរបស់គាត់និរទេសទៅកាន់ប្រទេសថៃ" ។ គួរឱ្យសោកស្ដាយ រូបភាពនោះគួរឱ្យចាប់អារម្មណ៍ណាស់ ដែលយើងប្រាថ្នាថាវាជាការពិត ប៉ុន្ដែមិនច្បាស់ថាវាជាការពិតទេ។ ម៉ី ម៉ាក់ (កិច្ចសម្ភាសន៍) ដែលដឹកនាំខាងស៊ីវិលនៅអាកាសយានដ្ឋានពោធិចិនតុង និយាយថាឧទ្ធម្ភាគចក្រមួយគ្រឿងបានចាកចេញពីខាងយោធានៅអាកាសយានដ្ឋាននៅល្ងាចថ្ងៃទី ៦ ខែ មករា ប៉ុន្ដែមិនច្បាស់ថាអ្នកណានៅក្នុងឧទ្ធម្ភាគចក្រនោះទេ។ ឧទ្ធម្ភាគចក្រចំនួនពីរគ្រឿងទៀត ត្រូវបានឃើញហោះចេញដោយអាកាសយានិកដោយការផ្ដើមគំនិតដោយខ្លួនឯងពេលព្រឹកនៅថ្ងៃបន្ទាប់ (ដូចជើងទំព័រខាងលើ, និង អ៊ុង ចុងហឿន, *Récit* ទំព័រ ១៦៤) ប៉ុន្ដែឧទ្ធម្ភាគចក្រភាគច្រើនដែលស្ថិតនៅលើផ្លូវរត់ និងមូលដ្ឋានកងទ័ពអាកាស ត្រូវបានកាន់កាប់ដោយពួកវៀតណាម។ *រថភ្លើងពិសេស៖* ឡុង វិសាឡូ, កិច្ចសម្ភាសន៍ និង អ៊ី ផាន់ដារ៉ា (*Retour* ទំព័រ ១៧៩-៨៩)។ អ្នកទាំងពីរ បានឃើញអៀង សារី ឡើងជិះរថភ្លើង។ ខ្លួនគាត់ផ្ទាល់ បានអះអាងថាបានធ្វើដំណើរទៅបាត់ដំបងតាមផ្លូវគោកជាមួយខៀវ សំផន (កិច្ចសម្ភាសន៍ជាមួយ *Maben*) ប៉ុន្ដែខៀវ សំផន បានបដិសេធការលើកឡើងនេះ (កិច្ចសម្ភាសន៍)។



Translated: [00396488-00396489]; [00396491]; [00396530]; [00396497-00396499]; [00396713-00396714]; [00396501-00396502]; [00396503-00396504]; [00396508-00396509]; [00396425]; [00396536]; [00396513]; [00396514]; [00396577-00396578]; [00396721]; [00396514-00396516]; [00396552-00396553]; [00396528]; [00396529]; [00396530]; [00396554]; [00396555]; [00396556]; [00396560]

[ERN 00396530]

នៅមុន ឬក្រោយសិសិររដូវបន្តិចក្នុងឆ្នាំ ១៩៧៥ ក្នុងកែវភ្នែកថ្នាក់ដឹកនាំប្រទេស ប្រជាពលរដ្ឋកម្ពុជាក្លាយជាចំនួនតួលេខនៅក្នុងតារាងតុល្យការជាតិ។

វាគ្មានវាចារនឹងថ្លែងទេ ដែលកម្មាភិបាលប្រើពាក្យគំរាមកំហែងពីរឃ្លានៅពេលពួកគេរៀបនឹងយកអ្នកណាម្នាក់ទៅសម្លាប់ថា "ទុកក៏មិនចំណេញ ដកចេញក៏មិនខាត។" ប្រជាជនម្នាក់នៅចាំសម្ដីនេះ គឺតម្លៃមនុស្សម្នាក់ត្រូវបានវាស់វែងដោយចំនួនម៉ែត្រគីបនៃដីដែលខ្លួនអាចរែកបាន។ ប្រជាជនធ្វើតាមបញ្ជាគេដូចសត្វពាហនៈដែរ។ ប្រជាជនជាឧបករណ៍មួយដែលត្រូវផ្ដល់អាហារ ទឹក ទីជម្រក និងដឹកនាំឲ្យធ្វើការ។ បន្ទាប់ពីពួកគេត្រូវបានសម្លាប់ សម្លៀកបំពាក់ត្រូវបានទាហានសម្រាតចេញដើម្បីប្រគល់ឲ្យអ្នកផ្សេងទៀត។ សាកសពត្រូវបានកប់ក្នុងវាលស្រែ ដោយសារពួកគេបានជំនឿថាសាកសពស្អុយរលួយនឹងក្លាយជាជីដ៏ល្អ។ អ្នកដែលស្លាប់ក្នុងមន្ទីរពេទ្យភូមិត្រូវបានបូជា ហើយផេះអដ្ឋិធាតុត្រូវបានប្រើជាជីហ្វូសហ្វាត។ ដូចគ្នាការស្លាប់ផងដែរ កម្មាភិបាលបានកំណត់ការចាប់កំណើត។ នៅពេលស្ត្រី ធ្លាក់រដូវ កម្មាភិបាលកត់សម្គាល់នូវរយៈពេលធ្លាក់រដូវរបស់ស្ត្រីដើម្បីរៀបចំឲ្យប្ដីរបស់ពួកគេមករួមដំណេកក្នុងរយៈពេលដែលអាចបន្តពូជបានល្អ ដើម្បីបង្កើនចំនួនប្រជាជនឲ្យបានច្រើន។

**ជើងទំព័រ៖**

៣២២. ***អ្នកដែលយើងធ្វើឲ្យភ្ញាក់ផ្អើល* [Those we suprised]** ៖ ដកស្រង់ក្នុង Martin, *បែកខ្ចាយ [Shatter]*, ទំព័រ ១៦៧-៨

ពាក្យពីរឃ្លា [Couplet], Locard, *កូនសៀវភៅក្រហម [Petit Livre Rouge]* ទំព័រ ១៧៥។ កេង វ៉ាន់សាក់យល់ឃើញថាឃ្លានេះ មានចេតនាបង្ហាញពីន័យត្រង់ថា "តម្លៃមនុស្សត្រូវបានបន្ថយមកត្រឹមជាវត្ថុសម្រាប់ភាពចំណេញ និងខាត" ។ (ដកស្រង់ក្នុង Burchett, *Triangle*, ទំព័រ៩៤)



Translated: [00396488-00396489]; [00396491]; [00396530]; [00396497-00396499]; [00396713-00396714]; [00396501-00396502]; [00396503-00396504]; [00396508-00396509]; [00396425]; [00396536]; [00396513]; [00396514]; [00396577-00396578]; [00396721]; [00396514-00396516]; [00396552-00396553]; [00396528]; [00396529]; [00396530]; [00396554]; [00396555]; [00396556]; [00396560]

[ERN 00396497-00396499]

ករណីសិក្សាសម្រាប់ភាពជារដ្ឋមានធនធានគ្រប់គ្រងដោយខ្លួនឯង (autarky) ត្រូវបានរៀបរៀងឡើងដោយ ខៀវ សំផន នៅក្នុងនិក្ខេបបទថ្នាក់បណ្ឌិតរបស់គាត់នៅ the Sorbonne ក្នុងឆ្នាំ ១៩៥៩។ គាត់សរសេរថា "សមាហរណកម្មអន្តរជាតិ ជាឫសគល់នៃការមិនរីកចម្រើននៃសេដ្ឋកិច្ចខ្មែរ"។ ជំនួយបរទេសធ្វើឱ្យប្រទេសពឹងផ្អែកលើទីផ្សារពិភពលោក ដែលកម្ពុជាមិនមានការគ្រប់គ្រង ពីព្រោះ ទីផ្សារពិភពលោក ត្រូវបានក្របដណ្ដប់ដោយផលប្រយោជន៍បរទេស។ ការដោះដូរពាណិជ្ជកម្មបរទេសច្រានសហគ្រិនក្នុងស្រុកចេញពីមុខជំនួយដោយសារលំហូរចូលយ៉ាងច្រើនសន្ធឹកសន្ធាប់នៃផលិតផលនាំចូលដែលមានតម្លៃថោក។

អាស្រ័យហេតុនេះ រដ្ឋមានធនធានគ្រប់គ្រងដោយខ្លួនឯង ឬ "ការអភិវឌ្ឍន៍ដែលមានស្វ័យភាព និងម្ចាស់ការដោយខ្លួនឯង" ដែលខៀវ សំផន ចូលចិត្តប្រើពាក្យនេះ ជាភាពចាំបាច់ជាក់លាក់។ ដើម្បីធ្វើឱ្យមានការអភិវឌ្ឍដែលមានស្វ័យភាព និងម្ចាស់ការដោយខ្លួនឯង វាចាំបាច់ត្រូវដាក់កម្រិតការដោះដូរពាណិជ្ជកម្មសេរី និងកំណត់ឡើងវិញនូវទំនាក់ទំនងរវាងបុគ្គល និងរដ្ឋ។

បុគ្គលម្នាក់ៗ រួមគ្នាបង្កើតជារដ្ឋ ហើយភាពរុងរឿងរបស់រដ្ឋមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ [ហើយពួកគេ] មិនអាចបំបែកចេញនូវជោគវាសនារបស់ពួកគេពីរដ្ឋដែលខ្លួនរស់នៅឡើយ...*អាស្រ័យហេតុនេះ សេដ្ឋវិទូគប្បីយកមកពិចារណាតថភាពជាសារវ័ន្តរបស់រដ្ឋ មិនមែនបុគ្គលឡើយ* [គូសបញ្ជាក់នៅក្នុងឯកសារដើម]។

ការកាត់បន្ថយចំនួនមនុស្សលចូលរួមជាទូទៅក្នុងកិច្ចការសង្គមកាន់ច្រើន មានន័យថាមនុស្សកាន់តែច្រើនអាចចូលរួមចំណែកក្នុងផលិតកម្ម ហើយរដ្ឋអាចទទួលបាននូវភោគទ្រព្យកាន់តែឆាប់រហ័ស...

អាស្រ័យហេតុនេះ ការរៀបចំសង្គមឱ្យបានសមស្រប ចាំបាច់ត្រូវខិតខំដាក់កម្រិតសកម្មភាពមិនបានការដើម្បីប្រើប្រាស់កម្លាំងប្រជាជនក្នុងចំនួនអតិប្បមារក្នុងការងារផលិតកម្ម។

"សកម្មភាពមិនបានការ" ដែលខៀវ សំផន លើកឡើងរួមមានវិស័យពាណិជ្ជកម្ម និងការិយាល័យធិបតេយ្យរបស់រដ្ឋាភិបាល។



Translated: [00396488-00396489]; [00396491]; [00396530]; [00396497-00396499]; [00396713-00396714]; [00396501-00396502]; [00396503-00396504]; [00396508-00396509]; [00396425]; [00396536]; [00396513]; [00396514]; [00396577-00396578]; [00396721]; [00396514-00396516]; [00396552-00396553]; [00396528]; [00396529]; [00396530]; [00396554]; [00396555]; [00396556]; [00396560]

ហ៊ូ យន់ ជានិស្សិតថ្នាក់បណ្ឌិតក្នុងប្រទេសបារាំង បានលើកឡើងនូវគំនិតស្រដៀងគ្នានេះដែរ។ ប៉ុន្តែវាមិនត្រឹមត្រូវក្នុងការចាត់ទុកនិក្ខេបបទទាំងនោះជាផែនការលម្អិតសម្រាប់ប្រព័ន្ធសេដ្ឋកិច្ចដែលខ្មែរក្រហមបានអនុវត្តក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧៥ ឡើយ។ បុរសទាំងពីរនេះ សង្កត់ធ្ងន់ទៅលើតួនាទីនៃបច្ចេកវិទ្យាដែលខុសពីចក្ខុវិស័យរបស់ប៉ុល ពត ហើយខៀវ សំផន ថែមទាំងលើកឡើងថាប្រទេសកម្ពុជាត្រូវការទម្រង់មួយនៃ “មូលធននិយមជាតិដោយមានស្វ័យភាព”។ ហ៊ូ យន់ ទទួចឲ្យមានការអភិវឌ្ឍតាមលំដាប់លំដោយនៃការអនុវត្តបែបសម្ហូហភាព។ ទោះជានេះក្តី និក្ខេបបទរបស់ពួកគាត់ ជាប្រធានបទនៃការពិភាក្សាវែកញែកក្នុងចំណោមជននិយមជ្រុលកម្ពុជាក្នុងទស្សវត្សរ៍ឆ្នាំ ១៩៥០ និងឆ្នាំ ១៩៦០ និងគោលគំនិតជាគន្លឹះជាច្រើននៃការពិសោធន៍របស់ខ្មែរក្រហម រួមមាន បឋមភាពសេដ្ឋកិច្ចសម្រាប់ជាតិជាជាងសម្រាប់បុគ្គល សេចក្តីសម្រេចចិត្តដោយម្ចាស់ការដើម្បីផ្តោតលើការងារក្នុងប្រទេស និងកាត់ផ្តាច់ទំនាក់ទំនងក្រៅប្រទេស និងការផ្លាស់ប្តូររចនាសម្ព័ន្ធទាំងស្រុងក្នុងសង្គមដើម្បីបង្កើនផលិតកម្មក្នុងកម្រិតអតិបរមា អាចត្រូវបានអង្កេតមើលក្នុងកិច្ចពិភាក្សាដែលបានកើតឡើងនៅពេលនោះ។ ខៀវ សំផន ទទួលស្គាល់ថាកម្មវិធីបែបនេះ តម្រូវឲ្យមាន “ការបោះជំហានថយក្រោយ” ប៉ុន្តែវាជាមធ្យោបាយតែមួយប៉ុណ្ណោះដើម្បីកសាងកម្លាំងខ្លាំងរបស់ជាតិក្នុងពេលអនាគត។

ប៉ុន្តែ យុត្តិសាស្ត្រដែលបានរៀបចំឡើងដោយគណៈកម្មាធិការអចិន្ត្រៃយ៍នៃ ប.ក.ក នៅក្នុងខែ ឧសភា ឆ្នាំ ១៩៧៥ បានបង្កឲ្យមានបញ្ហាដែលមិនអាចបូះពារយកជ័យជំនះបាន សូម្បីតែអ្នកសង្កេតការណ៍បរទេសដែលគាំទ្រខ្លួនក៏ដោយ។ វាមិនមែនជាបញ្ហាដ៏ខ្លាំងក្លានៃខ្លឹមសាររបស់វានោះទេ ទោះបីជាគោលនយោបាយនេះមានលក្ខណៈកាន់តែជ្រាលជ្រៅហួសហេតុ និងរឹងត្អឹងជាងអ្វីដែល ខៀវ សំផន និង ហ៊ូ យន់ បានប្រមើលឃើញក៏ដោយ។ បញ្ហា គឺស្ថិតនៅត្រង់មធ្យោបាយដែលត្រូវយកមកអនុវត្តចំពោះគោលនយោបាយនោះ “មិនសមហេតុផល ឬសុខក្សេមក្សាន្ត” ដូចអ្នកឯកទេសជនជាតិបារាំងម្នាក់និយាយថាវា “ឃោរឃៅ និងអមនុស្សធម៌”។

អ្វីដែល ប៉ុល ពត និងសហការីរបស់គាត់បានសម្រេចកាលពីនិទាឃរដូវកន្លងទៅនោះ គឺរដ្ឋទាសករលើកដំបូងនៅក្នុងសម័យទំនើប។

ពាក្យពេចន៍នេះ មានលក្ខណៈគួរឲ្យរំជួលចិត្ត និងតម្រូវឲ្យមានការកំណត់និយមន័យ។ Stalin, Hitler និងអ្នកកាន់អំណាចផ្តាច់ការដ៏សម្បូរបែបនៃប្រទេសតតីយលោក បានធ្វើឲ្យប្រជាជនរបស់ខ្លួនក្លាយជាទាសករតាមលក្ខណៈប្រៀបធៀប ដោយការដកហូតសិទ្ធិជាមូលដ្ឋាន និងសេរីភាពពីប្រជាជនទាំងនោះ។ ប៉ុល ពត



Translated: [00396488-00396489]; [00396491]; [00396530]; [00396497-00396499]; [00396713-00396714]; [00396501-00396502]; [00396503-00396504]; [00396508-00396509]; [00396425]; [00396536]; [00396513]; [00396514]; [00396577-00396578]; [00396721]; [00396514-00396516]; [00396552-00396553]; [00396528]; [00396529]; [00396530]; [00396554]; [00396555]; [00396556]; [00396560]

បានធ្វើឲ្យប្រជាជនកម្ពុជាក្លាយជាទសករដោយត្រង់ៗ ដោយការដាក់គុកច្រវ៉ាក់ពួកគាត់នៅក្នុងរចនាសម្ព័ន្ធសង្គម និងនយោបាយ ដែលក្រោយមក ជនភៀសខ្លួនបានហៅវាថាជា “គុកឥតជញ្ជាំង” ដែលតម្រូវឲ្យពួកគេធ្វើការកាប់សម្លាប់ដោយមិនចាំបាច់ពិចារណាអ្វីឡើយ ទោះជាការងារដែលបានប្រគល់ឲ្យពួកគេធ្វើនោះជាការងារអ្វីក៏ដោយ ឲ្យតែពួកកម្មាភិបាលបានដាក់បញ្ជាមក។ បើការខកខានមិនបានអនុវត្តតាម នោះពួកគេត្រូវប្រឈមមុខទៅនឹងការដាក់ទណ្ឌកម្ម គិតចាប់ពីការដកហូតរបបអាហារ រហូតដល់ការបាត់បង់អាយុជីវិត។ តាមទ្រឹស្តី ចំណីអាហារ និងសម្លៀកបំពាក់ ត្រូវបានរដ្ឋផ្តល់ជូន។ ប៉ុន្តែ មិនមានប្រាក់បៀវត្សរ៍អ្វីទេ។ នៅសហភាពសូវៀត ក្នុងអំឡុងនៃ “សង្គ្រាមសង្គមនិយម” នាដើមទសវត្ស ១៩២០ ក្នុងរចកាលយ៉ាន “Yan” នៃប្រទេសចិន រយពេលមួយទសវត្សក្រោយមក ឬ សូម្បីតែនៅក្នុងប្រទេសកូរ៉េខាងជើងនាសម័យកាលដំណាលៗគ្នានោះ ក៏យ៉ាងហោចណាស់ កម្មករត្រូវបានផ្តល់ប្រាក់ឧបត្ថម្ភតិចតួចដែរ។ ទោះបីជាមានចំនួនតិចតួចក៏ដោយ ក៏វាមានន័យថា ពួកគេជម្រើសខ្លះដែរ សូម្បីតែវាមានចំនួនមិនអាចទិញបារីលើសពីមួយកញ្ចប់ ឬសាប៊ូមួយដុំ ក្នុងមួយខែក៏ដោយ។ មានឱកាសតិចតួចណាស់សម្រាប់ការប្រើប្រាស់ឆន្ទៈសេរី។ របបខ្មែរក្រហមនៃប្រទេសកម្ពុជា មិនមានអ្វីទាំងអស់ ដែលបង្ហាញឲ្យឃើញពីភាពខុសគ្នាខាងគុណភាពដែលថា មានតែអ្នកដែលមានបទពិសោធក្នុងបញ្ហានេះទេ ទើបអាចយល់បាន។ មិនមែនគ្រាន់តែមិនមានប្រាក់កម្រៃនោះទេ គឺថែមទាំងមិនមានផ្សារទៀតផង។ នៅក្នុងអំឡុងពេលនោះ ដោយសារតែប្រព័ន្ធនេះកាន់តែមានភាពតឹងតែងឡើងៗ សូម្បីតែការផ្លោះប្តូរទំនិញក៏ត្រូវបានហាមឃាត់ដែរ។ ដូចគ្នានឹងទាសករពិតៗអញ្ចឹងដែរ ប្រជាជនដែលរស់នៅក្នុងប្រទេសកម្ពុជាក្រោមរបប ប៉ុល ពត ត្រូវបានគេដកហូតការគ្រប់គ្រងទៅលើជោគវាសនារបស់ខ្លួនទាំងអស់ គឺមិនអាចសម្រេចថាត្រូវហូបអ្វី ចូលទៅសម្រាន្តនៅពេលណា ទៅរស់នៅទីណា ឬក៏ត្រូវរៀបការជាមួយអ្នកណា។

មេដឹកនាំខ្មែរក្រហម សំខាន់បំផុតគឺ ប៉ុល ពត នេះឯងអាចជំទាស់នឹងការបកស្រាយនេះ។ ហើយវាជាការពិតដែលនៅក្នុងសុន្ទរកថារបស់គាត់ខ្លះ បានអំពាវនាវឲ្យកម្មាភិបាលមូលដ្ឋាន “ជួយលើកស្ទួយលទ្ធិប្រជាធិបតេយ្យដោយអង់អាចក្លាហាន”។ ប៉ុន្តែ តាមរយៈការអំពាវនាវនេះ គាត់គ្រាន់តែចង់មានន័យថា គួរតែអំពាវនាវឲ្យ “មហាជន” ផ្តល់ការគាំទ្រឲ្យបានសកម្មដល់របបនោះតែប៉ុណ្ណោះ ជាជាង “គ្រាន់តែបំពេញភារកិច្ចរបស់ចខ្លួនដូចម៉ាស៊ីនតែប៉ុណ្ណោះ”។ វាក៏ជាការពិតផងដែរថា មធ្យោបាយដែលប្រព័ន្ធថ្មីនេះបានយកមកបកស្រាយ គឺខុសគ្នាយ៉ាងសម្បើមពីភូមិភាគមួយទៅភូមិភាគមួយ ពីតំបន់មួយទៅតំបន់មួយទៀត ហើយសូម្បីតែពីភូមិមួយ



Translated: [00396488-00396489]; [00396491]; [00396530]; [00396497-00396499]; [00396713-00396714]; [00396501-00396502]; [00396503-00396504]; [00396508-00396509]; [00396425]; [00396536]; [00396513]; [00396514]; [00396577-00396578]; [00396721]; [00396514-00396516]; [00396552-00396553]; [00396528]; [00396529]; [00396530]; [00396554]; [00396555]; [00396556]; [00396560]

ទៅភូមិមួយក៏ខុសគ្នាដែរ។ នៅកន្លែងខ្លះ កម្មាភិបាលមានការអត់ឱន ឯនៅកន្លែងខ្លះទៀត កម្មាភិបាលមានភាពយង់ឃ្នង។ ប៉ុន្តែ នៅក្នុងស្ថានភាពទាំងពីរនេះ ប្រជាជនដែលជាទាសករមិនអាចជំទាស់អ្វីបានឡើយ។ ពួកគាត់ចេះតែខំអត់ទ្រាំទៅ ទោះជាភាពអនុគ្រោះ ឬភាពតឹងតែងនោះមានកម្រិតប៉ុណ្ណាក៏ដោយ ឲ្យតែ “ថ្នាក់លើ” កំណត់។



Translated: [00396488-00396489]; [00396491]; [00396530]; [00396497-00396499]; [00396713-00396714]; [00396501-00396502]; [00396503-00396504]; [00396508-00396509]; [00396425]; [00396536]; [00396513]; [00396514]; [00396577-00396578]; [00396721]; [00396514-00396516]; [00396552-00396553]; [00396528]; [00396529]; [00396530]; [00396554]; [00396555]; [00396556]; [00396560]

[ERN 00396713-00396714]

**ជើងទំព័រ៖**

២៨៩-៩០ ***មនុស្សទាំងអស់ត្រូវបែងចែកជាក្រុមៗ ... នៅតាមកន្លែងបង្កបង្កើនផល៖*** ខៀវ សំផន និក្ខេបបទ ទំព័រ ៣០, ៥០ ( ឯកសារបកប្រែដែលបានកែប្រែ) និងទំព័រ ៧៥-៦។

២៩០ ***"ផែនការ"៖ សារព័ត៌មានបាងកកប៉ុស្តិ៍*** ចេញផ្សាយនៅថ្ងៃទី ១៥, ១៧, ១៩, ២១, ២៣, និង ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៧៦។ "**Make sense**", សៀវភៅរបស់លោក Chandler, **បញ្ហាប្រឈមមុខ,** ទំព័រ ២១៣។ ***"តើពួកគេត្រូវបានគេរកឃើញដែរឬទេ?"៖*** អត្ថបទរបស់ **Joel R. Charny** ស្ដីពី "ជំនួយដើម្បីការអភិវឌ្ឍន៍ឱ្យបានសមស្របសម្រាប់ប្រទេសកម្ពុជា", នៅក្នុងសៀវភៅរបស់ Ablin និង Hood, ***សេចក្ដីឈឺចាប់បំផុត,*** ទំព័រ ២៥០។ **វត្ថុបំណងនៃមេរៀន៖** Meyer, Sourire, ទំព័រ ២១១-១៧ និងទំព័រ ២៨៣-៤។

២៩១ ***"មិនមែនផ្ទុយទៅនឹងវិចារណញ្ញាណនោះទេ"៖*** អត្ថបទរបស់ Pierre Brocheux, នៅក្នុងសៀវភៅរបស់ Camille Scalabrino និងអ្នកផ្សេងទៀត, ប្រទេសកម្ពុជា, ប្រវត្តសាស្ត្រ និង បញ្ហាប្រឈមមុខ៖ ឆ្នាំ ១៩៤៥-១៩៨៥, គ្រឹះស្ថានបោះពុម្ព L'Harmattan, ទីក្រុងប៉ារីស ឆ្នាំ ១៩៨៥ ទំព័រ ២៣០-១។ ***"ជម្រុញយ៉ាងមុះមុត ... ដូចម៉ាស៊ីន"*** ៖ ប៉ុល ពត របាយការណ៍ ទំព័រ ២០៦-៧។ សូមមើល ផងដែរ កិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ កាលពីថ្ងៃទី៣០ ខែ មីនា ឆ្នាំ ១៩៧៦ នៅក្នុងសៀវភៅរបស់ Chandler និងអ្នកផ្សេងទៀត។ ផែនការរបស់ ប៉ុល ពត, ទំព័រ ៣។

[ERN 00396501-00396502]

លើសពីនេះទៅទៀត នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ កសិករកម្ពុជាដែលជាអ្នកបានបង្កើតមូលដ្ឋានសម្រាប់បដិវត្តន៍របស់ខ្មែរក្រហមរស់នៅមិនខុសគ្នាឆ្ងាយពី ការរស់នៅរបស់ជីដូនជីតាពួកគេកាលពីប៉ុន្មានសតវត្សរ៍មុន ដែលបានប្រើប្រាស់ឧបករណ៍កសិកម្មតិចតួចជាងកសិករប្រទេសបារាំងនៅក្នុងមជ្ឈិមសម័យទៅទៀត។

ប៉ុន្តែ បញ្ហានេះមិនមានន័យថា ប៉ុល ពត មានបំណងបង្កើតអតីតកាលឡើងវិញនោះទេ។ គោលបំណងគឺមិនមែនធ្វើតាមសម័យអង្គរនោះទេ គឺធ្វើឲ្យលើសពីនេះទៅទៀត។

ជំហានទីមួយ តាមការយល់ឃើញរបស់ជនបដិវត្តន៍ គឺការកម្ទេចពួកសក្តិភូមិ ដែលបានគេងប្រវ័ញ្ចប្រទេសជាតិរាប់សតវត្សរ៍កន្លងមកហើយ ដើម្បីឈានទីបញ្ចប់របស់ពួកគេនោះ ត្រូវបានសម្រេចឡើងតាមរយៈជ័យជំនះរបស់ជនកុម្មុយនីស្ត និងការជម្លៀសប្រជាជនចេញពីទីក្រុងនានា។ ជំហានទីពីរ និងទីបី តាមពាក្យសម្តីរបស់ ប៉ុល ពត គឺ “ដើម្បីកសាង និងការពារ” មានន័យថា ការចល័តប្រជាជនទាំងមូលដើម្បីអភិវឌ្ឍឲ្យបានឆាប់រហ័ស ក្នុងគោលបំណងទប់ស្កាត់ខ្មាំងជាអចិន្ត្រៃយ៍របស់កម្ពុជា គឺប្រទេសថៃ និងប្រទេសវៀតណាម កុំឲ្យកេងយកប្រយោជន៍ពីរដ្ឋទន់ខ្សោយរបស់ខ្លួននេះ។ ការយល់ឃើញចុងក្រោនេះ មានសារៈសំខាន់ណាស់។

ប៉ុន្មានសតវត្សរ៍កន្លងមកនេះ ប្រទេសកម្ពុជាត្រូវបានហែកញ់ក់ញីដោយប្រទេសជិតខាងរបស់ខ្លួនទាំងពីរដែលមានអំណាច។ ការស្ថិតនៅក្រោមរបបអាណិគមនិយមបារាំង និងសង្គ្រាមរបស់ សហរដ្ឋអាមេរិក នៅក្នុងប្រទេសវៀតណាមបានអូសបន្លាយរយៈពេលប្រហែលមួយរយឆ្នាំឯណោះ។ ប៉ុន្តែ ពេលនេះ ពួកមហាអំណាចបានចាកចេញហើយ ប្រទេសកម្ពុជា ប្រទេសថៃ និងប្រទេសវៀតណាមត្រូវបានគេទុកឲ្យរៀបចំចាត់ចែងផែនការដោយខ្លួនឯង។ ចំពោះ ប៉ុល ពត នៅក្នុងឆ្នាំ ១៩៧៥ គាត់មិនយល់ឃើញថា ជម្លោះក្នុងតំបន់ថ្មីមួយនឹងជិតចូលមកដល់នោះទេ។ ប៉ុន្តែ ការខិតខំប្រើប្រាស់ឥទ្ធិពលឥតឈប់ឈររវាងពួកកុម្មុនីស្តកម្ពុជា និងពួកកុម្មុយនីស្តវៀតណាម នៅក្នុងអំឡុងសង្គ្រាមស៊ីវិល ការប្រយុទ្ធគ្នាជាហូរហែររវាងកងទ័ពដែលគេសន្មតថាជាកងទ័ពសម្ព័ន្ធមិត្តខ្មែរ និងវៀតណាម និងប្រវត្តិដ៏ច្របូលច្របល់នៃការវាយប្រយុទ្ធគ្នារប៉េះរប៉ោះនៅតាមព្រំដែននៅក្នុងអំឡុងរបប សីហនុ បានធ្វើឲ្យគាត់ជឿជាក់ថា ប្រទេសកម្ពុជាត្រូវរៀបចំខ្លួនដើម្បីតទល់នឹងការបង្កជម្លោះណាមួយនាពេលអនាគតពីរបបទីក្រុងហាណូយ។ ដូចដែលគាត់បានប្រាប់ទៅគណៈអចិតន្ត្រៃយ៍ថា “ប្រសិនបើយើងរត់ឲ្យលឿនបំផុត នោះប្រទេសវៀតណាមមិនអាចតាមយើងទាន់ទេ”។


Translated: [00396488-00396489]; [00396491]; [00396530]; [00396497-00396499]; [00396713-00396714]; [00396501-00396502]; [00396503-00396504]; [00396508-00396509]; [00396425]; [00396536]; [00396513]; [00396514]; [00396577-00396578]; [00396721]; [00396514-00396516]; [00396552-00396553]; [00396528]; [00396529]; [00396530]; [00396554]; [00396555]; [00396556]; [00396560]

គ្មានអ្វីគួរឲ្យឆ្ងល់នោះទេថា សូម្បីតែមិនមានការលើកទឹកចិត្តក៏ដោយ ក៏ ប៉ុល ពត បានដឹកនាំប្រទេសទៅដល់កម្រិតនៃការអត់ទ្រាំ និងលើសពីនេះទៅទៀត។ "ប្រសិនបើយើងមានបំណងការពារផ្លែផ្ការបស់បដិវត្តន៍ យើងមិនត្រូវបន្ធូរដៃទេ" ប៉ុត ពត បានប្រាប់ទៅសហការីរបស់គាត់។ "យើងត្រូវដំដែកទាន់នៅក្តៅ"។ សេដ្ឋកិច្ច គឺជាសមរភូមិមួយផ្សេងទៀតដែលត្រូវវាយដណ្តើមតាមរយៈកម្លាំងដ៏សាហាវ។

តើយើងត្រូវរៀបចំសកម្មភាព [របស់យើង] ដោយរបៀបណា? តើវាដូចគ្នានៅក្នុងសង្គ្រាមដែរឬទេ? យើងបានលើកឡើងពីគោលការវាយប្រយុទ្ធ ... នៅពេលណាដែលខ្មាំងចុះខ្សោយ។ សេដ្ឋកិច្ចក៏អញ្ចឹងដែរ។ យើងវាយប្រយុទ្ធនៅកន្លែងណាដែលយើងមានឱកាសល្អបំផុត ... ។ យើងត្រូវត្រៀមវាយសម្រុកនៅទូទាំងប្រទេស ... ។ យើងបានរៀនសូត្រពីសង្គ្រាម។ បើការបញ្ជាខ្លាំងហើយ យើងនឹងឈ្នះហើយ។ បើការបញ្ជាមិនខ្លាំងទេ យើងនឹងមិនឈ្នះទេ។ ការកសាងសេដ្ឋកិច្ចក៏ដូច្នេះដែរ។

ដោយសារតែវិធីសាស្ត្រដូចគ្នានេះហើយ ទើបបណ្តាលឲ្យបុរសៗរាប់រយពាន់នាក់ចូលប្រឡូកក្នុងការវាយប្រយុទ្ធឥតឈប់ឈរប្រឆាំងនឹងរដ្ឋាភិបាលទីក្រុងភ្នំពេញ ដោយមិនរួញរានឹងការរងរបួសស្នាម ដែលអាចបញ្ឈប់ការស្លាប់កងទ័ពរបស់ខ្លួននៅក្នុងពេលនោះតែម្តង។ ប៉ុល ពត បានប្រកាសថា នៅក្នុង "ការកសាងសង្គមនិយនម" គឺវាដូចគ្នានឹងការធ្វើសង្គ្រាមដែរ។

ថ្នាក់ដឹកនាំបក្សត្រូវតែអនុវត្តតួនាទីដឹកនាំរបស់ខ្លួន ដោយការប្រើប្រាស់អំពើហិង្សាដ៏មានប្រសិទ្ធភាព...។ នេះជាកត្តាដ៏សាមខាន់បំផុត ជាកត្តាដាច់ខាត ដែលជាអំណាចដែលជម្រុះញអ្វីៗទាំងអស់ឲ្យទៅមុខបាន។

ច្រើនឆ្នាំក្រោយមក អៀង សារី បានធ្វើអត្ថាធិប្បាយដោយយឺតពេលទៅហើយថា គេអាចគិតឃើញថា បងថ្លៃប្រុសរបស់គាត់មាន "ទស្សនៈយល់ឃើញដ៏ងាយបំផុតទៅលើបញ្ហាផ្សេងៗ"។

បើនិយាយពីគោលនយោបាយអភិវឌ្ឍន៍វិញ ចំណុចនេះបាននាំមកនូវយោធូនីយកម្មទាំងគំនិត និងភាសា។ ប្រជាជន "បានប្រយុទ្ធ" ចាប់ត្រី ឬប្រមូលជីជាតិ។ ពួកគេ "បានបន្តប្រយុទ្ធឥតឈប់ឈរ" ដើម្បី "បង្កបង្កើតផលជាយុទ្ធសាស្ត្រ"។ ពួកគេបានប្រយុទ្ធ "នៅជួរមុខ" (នៅការដ្ឋានលើកទំបន់ និងជីកប្រឡាយ) និង "នៅជួរ

ក្រោយ" (វាលស្រែនៅតាមភូមិ)។ ពួកគេបានបង្កើតជាក្រុម កងអនុសេនាធំ កងវរៈសេនាតូច កងពលតូចចល័ត និង កងវរៈសេនាធំ។ ពួកគេបានបង្ហាញឲ្យឃើញនូវ "សាមគ្គីភាពក្នុងការវាយប្រយុទ្ធ" ដើម្បីដណ្តើមយក "ជ័យជំនះ"។

វាជាទ្រឹស្តីនៃការវាយនឹងព្រនង់។ នៅឆ្នាំ ១៩៧៥ ទ្រឹស្តីនេះត្រូវបានសរសេរចូលទៅក្នុងឯកសារ/ហ្សែន (genes) របស់បក្ស។ មិនមានការគិតឃើញតាមមធ្យោបាយផ្សេងទៀតនោះទេ។ វាក៏ជាការពិតផងដែរថា ប៉ុល ពត និងថ្នាក់ដឹកនាំដទៃទៀតនៃបក្សកុម្មុយនីស្តកម្ពុជា បានប្រឈមមុខទៅនឹងបញ្ហាជាក់ស្តែងទាំងអស់ដែលមិនអាចដោះស្រាយបាន ដែលបានធ្វើឲ្យពួបារាំងទទួលបរាជ័យ ធ្វើឲ្យសម្តេច សីហនុ ទទួលបរាជ័យ និងបានធ្វើឲ្យគ្រប់រដ្ឋាភិបាលកម្ពុជាទទួលបរាជ័យតាំងពីនោះមក។

បញ្ហាគឺ ថាតើត្រូវឲ្យប្រជាជនខ្មែរយើងចេះធ្វើការដោយរបៀបណា។

**ជើងទំព័រ៖**

២៩៣ **"ប្រសិនបើប្រជាជនយើង"៖** ប៉ុល ពត, ***សុន្ទរកថា ចុះថ្ងៃទី ២៧ ខែ កញ្ញា បានធ្វើឲ្យគាត់ជឿជាក់៖*** **អ៊ិន សុភាព, សៀវ សំផន** ទំព័រ ៩៩-១០០។ **"រត់ឲ្យលឿន"៖** កំណត់ហេតុនៃកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ នៅក្នុងឯកសារលេខ ៣២ (N442)/T8355, VA។ "គ្មានភាពធូររលុង"៖ កិច្ចសម្ភាសន៍របស់ អ៊ិន សុភាព។ គាត់បានផ្តល់ជូននូវអត្ថបទមួយដែលមានលក្ខណៈខុសគ្នាបន្តិច នៅក្នុងសៀវភៅរបស់ ខៀវ សំផន ទំព័រ ១០៣។

២៩៤ **ត្រូវរៀបចំដោយរបៀបណា៖** របាយការណ៍របស់ ប៉ុល ពត ធ្វើជូនសន្និបាតបក្សភូមិភាគពាយ័ព្យ *ទស្សនាវដ្តីទង់បដិវត្តន៍* ចុះខែ មិថុនា ឆ្នាំ ១៩៧៦។ អត្ថបទបកប្រែត្រូវបានផ្តល់ជូនលោក Chandler និងអ្នកផ្សេងទៀត ផែនការរបស់ ប៉ុល ពត ទំព័រ ១៣-៣៥។ សម្រាប់ផ្នែកដែលបានដកស្រង់ សូមមើល ទំព័រ ២០ និង ២៦។ ឲ្យមុតស្រួច៖ សេចក្តីសម្រេចរបស់គណៈមជ្ឈិម ប.ក.ក ចុះខែ មិថុនា ឆ្នាំ ១៩៧៦ ឯកសារលេខ ៣២ (N442)/T8310, VA។ "ធូររលុង"៖ កិច្ចសម្ភាសន៍របស់ អៀង សារី។



Translated: [00396488-00396489]; [00396491]; [00396530]; [00396497-00396499]; [00396713-00396714]; [00396501-00396502]; [00396503-00396504]; [00396508-00396509]; [00396425]; [00396536]; [00396513]; [00396514]; [00396577-00396578]; [00396721]; [00396514-00396516]; [00396552-00396553]; [00396528]; [00396529]; [00396530]; [00396554]; [00396555]; [00396556]; [00396560]

[ERN 00396503-00396504]

ចំពោះអ្នកខ្លះ គេអាចមានភាពព្រងើយកន្តើយ តែចំពោះអ្នកខ្លះទៀត វាជាឧត្តមគតិ។ តែទោះជាក្នុងករណីណាមួយក៏ដោយ គឺវាផ្ទុយទៅនឹងរបៀបចាត់ចែងរបស់ប្រទេសជឿនលឿនហើយ។ ចំពោះ ប៉ុល ពត វាជាផ្លូវឆ្លងកាត់មួយដែលរារាំងដល់មហិច្ឆិតារបស់គាត់ក្នុងការធ្វើឲ្យប្រទេសកម្ពុជាមានការជឿលឿន និងខ្លាំង និងត្រូវតែកម្ទេចចោល។ គាត់បានពន្យល់អំពីការយល់ឃើញរបស់គាត់នេះ ដល់ជនកុម្មុយនីស្តដែលមានសមានចិត្ត គឺប្រធានគណៈបក្សថៃ Khamtan ថា៖ "ចរិតលក្ខណៈរបស់កសិករ គឺតែងតែធ្វេសប្រហែស ខ្វះសេចក្ដីក្លាហាន និងខ្វះទំនុកចិត្តលើខ្លួនឯង" គាត់បាននិយាយ។ ពួកគាត់ចេះតែធ្វើការតាមបញ្ជាតែប៉ុណ្ណោះ"។ ដូចមានរួចស្រេចទៅហើយ នៅមុនជ័យជំនះរបស់ពួកកុម្មុនីស្ត អ្នកសារព័ត៌មានជនជាតិអាមេរិកឈ្មោះ Donald Kirk ដែលមានទស្សនៈយល់ឃើញជាមុន បានកត់សំគាល់ថា ខ្មែរក្រហមបានសម្រេចយកគោលនយោបាយតឹងរ៉ឹងដោយចេតនា ដើម្បីកែប្រែ "មហាជនកសិករដែលស្ពឹកស្រពន់"។ ក្រោយឆ្នាំ ១៩៧៥ វិធីសាស្ត្រនេះត្រូវបានគេយកមកអនុវត្តនៅទូទាំងប្រទេស។

ការអនុវត្តរបស់ពួកខ្មែរក្រហមដែលបានក្លាយជាភារកិច្ចចម្បងនៃការដឹកនាំដោយលាក់មុខ សម្ងាត់ និងជាសមូហភាពបានដឹងឮដល់ប្រជាជនត្រឹមតែជាអង្គការប៉ុណ្ណោះ។ អង្គការជាពាក្យដែលគេប្រើប្រាស់បានច្រើនយ៉ាង។ អង្គការជារបបនៅគ្រប់កម្រិតថ្នាក់ ចាប់ពី ប៉ុល ពត និង គណៈកម្មាធិការអចិន្ត្រៃយ៍ដល់ឈ្លបភូមិដែលមានថ្នាក់ទាបបំផុត។ អង្គការមានអំណាចផ្ដាច់ការ សាហាវ មិនចេញមុខ និង ដាច់ស្រយាល ដែលជាបង្កើតនូវភាពបរិសុទ្ធបដិវត្តដែលតម្រូវឲ្យទទួលបានការគោរពស្មើរតែដូចគ្នាទៅនឹងសាសនា ពីអ្នកទាំងអស់ដែលអង្គការត្រូវដោះស្រាយ។ លោក កេង វ៉ាន់សាក់ រៀបចម្បងដែលជួយបង្អាត់បង្ហាញ ប៉ុល ពត បានហៅវាថា៖

វាជាក្បាលម៉ាស៊ីនដ៏មហិមាមួយសម្រាប់ការបង្ក្រាប និងការធ្វើឲ្យមានភាពភ័យតក់ស្លុត ដែលជាការចម្រុះចូលគ្នារបស់បក្ស រដ្ឋាភិបាល និង រដ្ឋ មិនមែនស្ថិតនៅក្នុងការយល់ដឹងជាធម្មតារបស់ស្ថាប័នទាំងនោះទេ ប៉ុន្តែ វាមានសង្កត់ន័យពិសេសទៅលើចរិតលក្ខណៈជាអាថ៌កំបាំង គួរឲ្យភ័យខ្លាច និងគ្មានមេត្តា។ តាមរបៀបមួយគឺវាជាអំណាចនយោបាយដែលពិបាកយល់ អនាមិក មាននៅគ្រប់ទីកន្លែង ដឹងសព្វគ្រប់ ចេះតែរីករាយដាលឡើងដោយការសាបព្រោះនូវសេចក្ដីស្លាប់ និង ភាពភ័ខ្លាចដោយសារឈ្មោះរបស់អង្គការនេះឯង។

**ជើងទំព័រ៖**



Translated: [00396488-00396489]; [00396491]; [00396530]; [00396497-00396499]; [00396713-00396714]; [00396501-00396502]; [00396503-00396504]; [00396508-00396509]; [00396425]; [00396536]; [00396513]; [00396514]; [00396577-00396578]; [00396721]; [00396514-00396516]; [00396552-00396553]; [00396528]; [00396529]; [00396530]; [00396554]; [00396555]; [00396556]; [00396560]

២៩៥ **រយៈពេលប្រាំមួយខែរ:** និក្ខេបបទរបស់ ខៀវ សំផន, ទំព័រ ៧៩។ Smith, ដំណើររឿងដែលបានបk ស្រាយ, ទំព័រ ៥។ **ព្រះពុទ្ធ**, Schecter, មុខមាត់ថ្មីនៃព្រះពុទ្ធសាសនា, Coward-McCann, ទីក្រុងញូវយ៉ក, ឆ្នាំ ១៩៧៦ ទំព័រ ៧។ ***បទពិសោធន៍ដែលត្រូវបានរៀបរាប់លំអិត***,សីហនុ, សង្គ្រាមរបស់ខ្ញុំ ទំព័រ ១២៣-២៤។ **ស្គរភ្នោត:** កិច្ចសម្ភាសន៍របស់ លី ហៃ។ **គាត់បានពន្យល់ ... ការធ្វើតាមបញ្ជា**, ប៉ុល ពត , ការសន្ទនាជាមួយ Khamtan។ “គ្មានអំណាច”៖ Kirk, បដិវត្ត, ទំព័រ ២២២។

២៩៦ ក្បាលម៉ាស៊ីនដឹកនាំដ៏មហិមា: ដកស្រង់ចេញពីក្នុងសៀវភៅរបស់ Bruchett, ត្រីកោណ, ទំព័រ ៩៥។ ប៉ុល ពត, របាយការណ៍ ទំព័រ ២០៧។ ភាពចាំបាច់ដើម្បីបំពេញការងារ: អៀង សារី, Der Spiegel, ចុះថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ១៩៧៧។



Translated: [00396488-00396489]; [00396491]; [00396530]; [00396497-00396499]; [00396713-00396714]; [00396501-00396502]; [00396503-00396504]; [00396508-00396509]; [00396425]; [00396536]; [00396513]; [00396514]; [00396577-00396578]; [00396721]; [00396514-00396516]; [00396552-00396553]; [00396528]; [00396529]; [00396530]; [00396554]; [00396555]; [00396556]; [00396560]

[ERN 00396508-00396509]

ម៉ៅ ពេញចិត្តនឹងភាពក្លាហានរបស់ ប៉ុល ពត នៅក្នុងការពង្រឹងប្រជាជនពីទីក្រុង។ នៅសរទរដូវនោះ គាត់បានសួរទៅកាន់ ឡេ ដុង ថាតើប្រទេសវៀតណាមអាចធ្វើដូចគ្នានេះបានដែរឬ អត់។ នៅពេលដែលមេដឹកនាំគ្រវីក្បាល ម៉ៅ បាននៅស្ងៀមមួយសន្ទុះ ហើយក្រោយមកបានយល់ស្របថា: "អត់បានទេ។ យើងក៏មិនអាចធ្វើដូចនេះបានដែរ"។

នៅចុងបញ្ចប់នៃអាយុដ៏វែងរបស់គាត់ លោកប្រធានមានភាពឈ្លាសវៃគ្រប់គ្រាន់ដោយយល់ឃើញថាពិភពលោកថ្មីដែលប្រជាជនកម្ពុជាបានសុបិន្តនោះ អាចបញ្ជាក់ថាការបំភាន់ភ្នែក។ ប្រទេសចិនបានព្យាយាមដើរតាមផ្លូវនេះរួចហើយ ប៉ុន្តែ បានបដិសេធគំនិតនេះចោលដោយសារវាមិនអាចអនុវត្តបាន។ ការបិទសាលារៀននិងសាកលវិទ្យាល័យជាបណ្ដោះអាសន្ន នៅក្នុងអំឡុងបដិវត្តវប្បធម៌បាននាំឱ្យមានបញ្ហាជាច្រើនដែលប្រទេសចិនបានដោះស្រាយ។ សូម្បីតែ ម៉ៅ ខ្លួនឯងក៏បានទទួលស្គាល់នៅពេលនេះថា មហាលោតផ្លោះ មហាអស្ចារ្យនៅចុងទសវត្សរ៍ឆ្នាំ ១៩៥០ ជាចលនាមហាជនដែលបានស្រមៃដ៏អស្ចារ្យមួយ ដែលមានបំណងតាមឱ្យទាន់ប្រទេសអង់គ្លេស និងអាមេរិកនៅក្នុងទិន្នផលសេដ្ឋកិច្ច និង ចាប់ដំណើរការទៅកុម្មុយនីស្តដោយផ្ទាល់ ប៉ុន្តែ ជាលទ្ធផលបានបណ្ដាលឱ្យប្រជាជនស្លាប់អស់ ២០ លាននាក់ដោយសារតែការអត់ឃ្លាននោះ គឺជាគ្រោះមហន្តរាយដ៏ធំមួយ។ ប៉ុន្តែ នៅពេលដែល ជូ អេនឡាយ ចុះខ្សោយសម្រាកនៅក្នុងមន្ទីរពេទ្យដោយសារជម្ងឺមហារីកបានព្យាយាមដាស់តឿន ខៀវ សំផន ថា មាគ៌ាឆ្ពោះទៅកាន់សង្គមនិយម គឺវែងឆ្ងាយ ហើយប្រទេសកម្ពុជាមិនគួរធ្វើតាមកំហុសរបស់ប្រទេសចិនឡើងវិញនោះទេ ហើយគាត់បញ្ចេញស្នាមញញឹមទាំងគ្មានជំនឿ។

ចាប់តាំងពីពេលនោះមក បក្សទាំងពីរកម្របាននិយាយគ្នាអំពី បញ្ហាមនោគមន៍វិជ្ជាណាស់ ហើយនៅពេលណាដែលពួកគេនិយាយពីបញ្ហានេះ ពួកគេមិនអាចយល់ស្របគ្នាបានទេ។

**ជើងទំព័រ៖**

៣០០ **ការពេញចិត្ត:** សូមមើល ប្រតិចារឹកនៅក្នុងប័ណ្ណសារដ្ឋានមជ្ឈិមប្រទេសចិនស្ដីពីកិច្ចប្រជុំរបស់ ម៉ៅ ជាមួយសម្ដេច សីហនុ, ប៉ែន នុត, ខៀវ សំផន និង ខៀវ ធីរិទ្ធ កាលពីថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ១៩៧៧ ដែលនៅពេលនោះ គាត់បានយល់ស្របយ៉ាងច្បាស់លាស់ចំពោះគោលនោយបាយជម្លៀសប្រជាជនចេញពីទីក្រុងនានា។ "អត់បានទេ។ **យើងក៏មិនអាចធ្វើដូចនេះបានដែរ"៖** សូមមើល ប្រតិ



Translated: [00396488-00396489]; [00396491]; [00396530]; [00396497-00396499]; [00396713-00396714]; [00396501-00396502]; [00396503-00396504]; [00396508-00396509]; [00396425]; [00396536]; [00396513]; [00396514]; [00396577-00396578]; [00396721]; [00396514-00396516]; [00396552-00396553]; [00396528]; [00396529]; [00396530]; [00396554]; [00396555]; [00396556]; [00396560]

ចារឹកស្តីពីកិច្ចប្រជុំរបស់ ម៉ៅ ជាមួយ ឡេ ដុង នៅទីក្រុងប៉េកាំង កាលពីថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៧៥ ដែលត្រូវបានរក្សាទុកនៅបណ្ណសាររដ្ឋានមជ្ឈិមប្រទេសចិន។

៣០១ **ស្នាមញញឹមទាំងគ្មានជំនឿ:** ប្រតិចារឹកនៃកិច្ចប្រជុំរបស់ ជូ អេនឡាយ ជាមួយសម្តេច សីហនុ និង ខៀវ សំផន នៅទីក្រុងប៉េកាំង កាលពីថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៧៥ ដែលត្រូវបានរក្សាទុកនៅក្នុងបណ្ណសាររដ្ឋានមជ្ឈិមប្រទេសចិន។ សូមមើលផងដែរ សម្តេច សីហនុ, មេដឹកនាំពិភពលោក ទំព័រ ៩៩-១០០។ **ការមិនយល់ស្របគ្នា:** សូមមើល ប្រតិចារឹកនៃកិច្ចប្រជុំរបស់ ប៉ុល ពត ជាមួយ Hua Guofeng កាលពីថ្ងៃទី ២៩ និង ៣០ ខែ កញ្ញា ឆ្នាំ ១៩៧៧ ដើម្បីជាឧទាហរណ៍នៃការមិនយល់ស្របគ្នាមួយទៅលើតួនាទីរបស់បក្សកាន់អំណាចដែលមិនមែនជាកុម្មុយនីស្ត នៅក្នុងអាស៊ីអាគ្នេយ៍ (ឯកសារលរបស់បក្សកាន់អំណាចដែលមិនមែនជាកុម្មុយនីស្ត នៅក្នុងអាស៊ីអាគ្នេយ៍ (ឯកសារលេខ 32(N442)/T8300, VA)។ **រយៈពេលបួនថ្ងៃក្រោយមក ... បានស្វាគមន៍ពួកគេ:** កិច្ចសម្ភាសន៍ជាមួយ អៀង សារី និង ម៉ី មាឃ។



Translated: [00396488-00396489]; [00396491]; [00396530]; [00396497-00396499]; [00396713-00396714]; [00396501-00396502]; [00396503-00396504]; [00396508-00396509]; [00396425]; [00396536]; [00396513]; [00396514]; [00396577-00396578]; [00396721]; [00396514-00396516]; [00396552-00396553]; [00396528]; [00396529]; [00396530]; [00396554]; [00396555]; [00396556]; [00396560]

[ERN 00396425]

នៅពេលនោះ ខ្ញុំមនទាំងបានដឹងថាមន្ទីររបស់ ប៉ុល ពត នៅទីណាផង។ អ្វីៗទាំងអស់ត្រូវបានដាក់ឲ្យដាច់ស្រឡះពីគ្នាយ៉ាងតឹងរ៉ឹង ...។ មន្ទីរទាំងអស់ស្ថិតនៅឆ្ងាយពីគ្នាប្រហែលពីមួយម៉ៃល៍ ឬ ពីរម៉ៃពីគ្នា ប៉ុន្តែ មន្ទីរនីមួយៗស្ថិតនៅក្នុងតំបន់របស់ខ្លួន។ នៅក្នុងមន្ទីររបស់ ប៉ុល ពត ស្ថានភាពរស់នៅគឺដូចគ្នាបេះបិទទៅនឹងកន្លែងផ្សេងទៀត ...។ ប៉ុន្តែ សូមឲ្យខ្ញុំជម្រាបលោកពីរឿងរ៉ាវមួយ។ នៅពេលដែលខ្ញុំបានដល់ ខ្ញុំបាននិយាយទៅកាន់អ្នកដទៃទៀត ដោយមិនបានគិតអ្វីទាំងអស់ថា "ខ្ញុំតែងតែឃើញអ្នកឯងសាងសង់ជំរុំនៅក្បែរមាត់ទឹក" ដោយសារមន្ទីររបស់ ប៉ុល ពត ដូចជាមន្ទីរ ស-៣១ ស្ថិតនៅក្បែរច្រាំងទន្លេ។ នេះគឺជាអ្វីដែលគេបានរាយការណ៍ត្រឡប់មកវិញ ហើយពីរ ឬ បីថ្ងៃក្រោយមក យុន យ៉ាយ បានកោះហៅខ្ញុំ។ គាត់បាននិយាយថា ខ្ញុំមិនត្រូវនិយាយបែបនេះទេ ខ្ញុំត្រូវតែបង្ហាញពី "ការប្រុងប្រយ័ត្នបដិវត្តន៍" ...។ តាមរបៀបមួយ គាត់និយាយត្រូវ។ ប្រសិនបើខ្មាំងកត់សម្គាល់បាន វាអាចជាសញ្ញាណមួយប្រាប់អំពីទីតាំងដែលទីបញ្ជាការនោះស្ថិតនៅ។ ប៉ុន្តែ នៅពេលដែលគាត់និយាយបែបនោះ វាបានធ្វើឲ្យខ្ញុំយល់ថា ពួកគេទាំងនេះមានស្មារតី "ប្រុងប្រយ័ត្នបដិវត្តន៍" ដែលគួរឲ្យព្រួយបារម្ភមែនទែន។ ពួកគេលាក់ការណ៍សម្ងាត់ខ្លាំងមែនទែន សូម្បីតែនៅក្នុងទីបញ្ជាការរបស់ពួកគេក៏ដោយ។ វាជារោគឆ្កួតលីលាហើយ។ អនុលេខារបស់ ប៉ុល ពត គឺ នួន ជា ក៏មានការប្រុងប្រយ័ត្នដូចគ្នានេះដែរ។ មូលហេតុចម្បងគឺ ជំនឿស៊ប់របស់ថ្នាក់ដឹកនាំ ដែលតាមសម្ដីរបស់ ខៀវ សំផន ថា "ខ្មែរមិនអាចរក្សាការសម្ងាត់បានទេ" ហើយហេតុដូច្នេះ ត្រូវតែយកមធ្យោបាយពិសេសៗមកប្រើប្រាស់ដើម្បីបង្ខំឲ្យពួកគេធ្វើបែបនេះ។ ចំណុចហួសហេតុចុងក្រោយស្ទើរតែទាំងអស់របស់របបខ្មែរក្រហម យ៉ាងហោចណាស់ក៏អាចត្រូវបានរកឃើញខ្លះៗ ចំពោះការយល់ឃើញថា ការបរាជ័យដែលមានតាំងពីធម្មជាតិរបស់ប្រជាជនកម្ពុជាអាចយកជ័យជំនះបានតែតាមរយៈលទ្ធិផ្ដាច់ការខ្លាំងក្លា និងការក្ដោបក្ដាប់ដែលមិនអាចមានលទ្ធភាពងាកចេញបាន ហើយម្នាក់ៗអាចត្រូវបានបង្ខំឲ្យចូលរួមពាក់ព័ន្ធ ដើម្បីជាប្រយោជន៍តាំងអស់គ្នា ដោតយការខិតខំប្រឹងប្រែងរួមគ្នាឥតស្រាកស្រាន និងមិនគិតពីប្រយោជន៍ខ្លួនឯង។



Translated: [00396488-00396489]; [00396491]; [00396530]; [00396497-00396499]; [00396713-00396714]; [00396501-00396502]; [00396503-00396504]; [00396508-00396509]; [00396425]; [00396536]; [00396513]; [00396514]; [00396577-00396578]; [00396721]; [00396514-00396516]; [00396552-00396553]; [00396528]; [00396529]; [00396530]; [00396554]; [00396555]; [00396556]; [00396560]

[ERN 00396536]

ហាំង ង៉ោ ដែលជាតារាក្នុង*រឿងវាលពិឃាតទវា*ពេលអនាគតបានគិតឃើញថា ប្រសិនបើរបបនោះមិនធ្វើឲ្យមានការភ័យខ្លាច និងអនុញ្ញាតឲ្យមានសេរីភាពច្រើនបន្តិច "ខ្ញុំនឹងអាចទទួលយកជោគវាសនារបស់ខ្ញុំបាន ហើយខ្លាយជាកសិករអស់ពីចិត្តពីថ្លើម"។ អ្នកជំនួញជនជាតិចិនម្នាក់បាននិយាយតាំងតឹកមុខស្លូតថា វាជា "ជីវិតរស់នៅដូចធម្មតា លើកលែងតែថា អ្នកមិនអាចចាយលុយបានទេ"។ ការអត់ធ្មត់របស់បុរសស្ត្រីដែលប៉ុន្មានខែមុន ជាក្រុមវរជនដែលមានអភ័យឯកសិទ្ធិ បានផ្តល់មេរៀនយ៉ាងក្រៀមក្រោះមួយក្នុងភាពរឹងមាំនៃស្មារតីមនុស្សជាតិ។ "ប្រជាជនមូលដ្ឋាន" ពុំត្រូវបានធ្វើតេស្តតាមវិធីដូចគ្នានេះឡើយ។ សេរីភាពដែលអ្នកទីក្រុង បានបាត់បង់ គឺសេរីភាពដែលពួកគាត់មិនដែលបានមានពីមុនមក។

ប្រាកដណាស់ វាមានភាពអាប់រស្មី និងគ្មានភាពរីករាយ។ ប៉ុន្តែនោះគឺជាអ្វីដែលមេដឹកនាំរបស់ខ្លួនចង់បាន។ ពុទ្ធសាសនាមហាយានបានបង្រៀនថា *និព្វាន្ត* ភពដែលគ្មានអ្វីជារបស់ខ្លួន អាចសម្រេចទៅបាននៅពេលដែល "ការស្រេកឃ្លានចង់បានអត្តិភាព" ដែលបង្កើតឡើងដោយចំណងផ្លូវចិត្តនិងចំណងលោកិយ៍ ត្រូវបានពន្លត់ទាំងស្រុង។ ក្រោមការគ្រប់គ្រងរបស់ ប៉ុល សេចក្តីស្រឡាញ់ ទុក្ខព្រួយ កំហឹង សេចក្តីត្រេកត្រអាល និងអារម្មណ៍ទាំងអស់ផ្សេងទៀត ដែលមានក្នុងជីវិតរស់នៅប្រចាំថ្ងៃ ត្រូវបានចាត់ទុកជាការបង្កើតស្វនត្តនិយមដែលត្រូវកម្ចាត់ សម្រាប់ផលប្រយោជន៍សមូហភាព។ នៅតាមបណ្តាប៉ែកខ្លះនៃប្រទេសនេះ មានការហាមឃាត់សូម្បីតែសើច ឬច្រៀង។ ក្នុងការស្វែងរកនិព្វាន្ត ប្រជាជនត្រូវតែរងទុក្ខវេទនា។

ជើងទំព័រ៖

៣២៧-៨ *កាន់តែសំខាន់ជាធម្មតា ... ចាយលុយ៖* ពិន យ៉ាថៃ, *ជីវិតកូនថ្លៃកូនត្រូវតែរស់,* ទំព័រ ៤៧។ Stuart-Fox, *បដិវត្តឃាតកម្ម,* ទំព័រ ៤៦។ ហាំង ង៉ោ, *Odyssey,* ទំព័រ ២៦៩, Ponchaud, *ឆ្នាំសូន្យ,* ទំព័រ ១៨៣ និង *Cathedrale,* ទំព័រ ២៣៦-៧, Edwards, *ជាតិពន្ធុចិន,* ទំព័រ ១៤៥។



Translated: [00396488-00396489]; [00396491]; [00396530]; [00396497-00396499]; [00396713-00396714]; [00396501-00396502]; [00396503-00396504]; [00396508-00396509]; [00396425]; [00396536]; [00396513]; [00396514]; [00396577-00396578]; [00396721]; [00396514-00396516]; [00396552-00396553]; [00396528]; [00396529]; [00396530]; [00396554]; [00396555]; [00396556]; [00396560]

[ERN 00396513]

ប៉ុល បានចំណាយខែ សីហា ធ្វើដំណើរក្នុងភូមិភាគនិរតី និងភូមិភាគបូព៌ា ដើម្បីបានឃើញផ្ទាល់ភ្នែកថាតើតំបន់ជនបទបានកំពុងដោះស្រាយបញ្ហាការហូរចូលដូចទឹកជំនន់នៃអ្នកទីក្រុងដែលត្រូវបានគេនិរទេស។ បន្ទាប់មក នាពាក់កណ្តាលខែ កញ្ញា គាត់បានកោះប្រជុំគណៈកម្មាធិការមជ្ឈិមមួយនៅភ្នំពេញ ដែលគាត់បានគូសបញ្ជាក់លម្អិតអំពីចក្ខុវិស័យរបស់គាត់អំពីអនាគតកម្ពុជា៖

យើងត្រូវតែកំណត់កូតាសម្រាប់ផលិតកម្ម [កសិកម្ម] ហើយសម្រាប់ការបែងចែកផលទុនគ្រប់ថ្នាក់-ថ្នាក់ភូមិ, ស្រុក តំបន់ និងភូមិភាគ...មួយផ្នែកគួរទៅ...ប្រជាជនសម្រាប់អាហាររបស់ពួកគាត់ និងដោះដូរជាមួយរដ្ឋសម្រាប់ឱសថ និងរបស់ចាំបាច់ដទៃទៀត។ មួយផ្នែកគួរទៅរដ្ឋ ដើម្បីប្រើប្រាស់សម្រាប់លើកកម្ពស់ជីវភាពប្រជានសម្រាប់ការការពារនិងកសាងជាតិ... ក្រោយមក [នៅពេល] សហករណ៍ត្រូវបានបង្កើតឡើងគ្រប់ទីកន្លែង...ពួកគាត់នឹងអនុវត្តភារកិច្ចកសាងសាលារៀន ឱសថាល័យ និងរោងជាង...ស្រុកអាចរក្សាទុកទុនបន្តិចបន្តួច ប៉ុន្តែមិនច្រើន គឺត្រឹមតែល្មមដើម្បីសម្របសម្រួលកម្លាំងពលកម្ម។ តំបន់ទាំងនោះអាចមានច្រើនជាងនេះបន្តិចដើម្បីសង់មន្ទីរពេទ្យ ទិញថ្នាំសង្កូវ និងធ្វើការស្រាវជ្រាវកសិកម្ម និងរក្សាអង្គភាពអ្នកបច្ចេកទេស ...

ដើម្បីអភិវឌ្ឍន៍សុខាភិបាលសាធារណៈ [យើងគួរ] ប្រើប្រាស់ទាំងឱសថបុរាណ [និង] ទិញឱសថសម័យពីបរទេសដើម្បីដោះដូរជាមួយ [ការនាំចេញ] ស្រូវ និងកៅស៊ូ... [យើងត្រូវតែ] លុបបំបាត់ជំងឺគ្រុនចាញ់...មានជំងឺផ្សេងៗទៀតផងដែរដើម្បីប្រយុទ្ធប្រឆាំងដូចជា ឃ្លង់ កញ្ជ្រិល និង ពក ក។ ចំពោះជំងឺនីមួយៗ យើងត្រូវតែស្វែងរកយុទ្ធសាស្ត្រ។

យើងត្រូវតែបង្កើតកន្លែងមើលកុមារ និងសាលាមត្តេយ្យ ដើម្បីរំដោះថាមពលនៃស្ត្រីរបស់យើង... យើងត្រូវគិតអំពីការអភិវឌ្ឍន៍ការអប់រំ និងវប្បធម៌។

**ជើងទំព័រ៖**

៣០៥-៦ ***យើងត្រូវតែកំណត់...មហាជន៖*** សម្រង់ក្នុង អ៊ិន សុភាព, *ខៀវ សំផន* ទំព័រ ១០៨-១០។



Translated: [00396488-00396489]; [00396491]; [00396530]; [00396497-00396499]; [00396713-00396714]; [00396501-00396502]; [00396503-00396504]; [00396508-00396509]; [00396425]; [00396536]; [00396513]; [00396514]; [00396577-00396578]; [00396721]; [00396514-00396516]; [00396552-00396553]; [00396528]; [00396529]; [00396530]; [00396554]; [00396555]; [00396556]; [00396560]

[ERN 00396514]

ប៉ុល បានប្រកាសថាកូតាផលិតកម្មជាមូលដ្ឋានដែលត្រូវអនុវត្តទូទាំងប្រទេស គឺ៣តោនស្រូវក្នុង១ហិកតា។ នៅលើក្រដាស នេះមិនមែនមិនមានភាពសមហេតុផលនោះឡើយ យ៉ាងហោចណាស់ក្នុងលក្ខណៈជាគោលដៅរយៈពេលវែង។ សីហនុ បានដាក់គោលដៅមួយហិកតា២តោន ហើយការពិសោធន៍សាកល្បងពុំមានការលំបាកក្នុងការឈានដល់ ៣ ឬ ៤ តោនឡើយ។ ប៉ុន្តែ ក្នុងប្រទេសមួយដែលទិន្នផលជាប្រវត្តិសាស្ត្រ បានចំនួនជាមធ្យមត្រឹមតែជាង១តោនស្រូវក្នុងមួយហិកតា ដែលស្ថិតក្នុងចំណោមទាបបំផុតនៅអាស៊ី វានៅតែពិបាកសម្រេចបាន។ លើសពីនេះ ដើម្បីសម្រេចផែនការនេះបានតម្រូវឱ្យប្រើប្រាស់ជាទ្រង់ទ្រាយធំនូវជីគីមី ដែលកម្ពុជាពិតជាគ្មាន៖ជំនួសវិញ ប៉ុល បានស្នើឡើងនូវការប្រើប្រាស់ "អាចមន៍សត្វ ដីល្បប់ ដីដំបូក អាចមន៍ប្រចៀវ ។ល។ និង ។ល។" ដែលតាមជីវសាស្ត្រ មិនអាចផលិតបានទិន្នផលតាមការទាមទាររបស់គាត់បានឡើយ។ នៅក្នុងការមិនស៊ីសង្វាក់គ្នានេះ មានមូលហេតុមួយក្នុងចំណោមមូលហេតុធំៗនៃវដ្តដ៏សាហាវនៃការបង្ក្រាបគ្រោះទុរភិក្ស និងការបង្ក្រាបបន្ថែមដែលទីបំផុតទៅធ្វើឱ្យរបបនេះដួលរលំ។

ការសម្រេចដ៏សំខាន់ដូចគ្នាមួយទៀតត្រូវបានធ្វើដោយក្រុមនោះនាខែនោះ៖ ការមិនប្រើប្រាស់លុយ។

ជើងទំព័រ- ទំព័រ ៤៩៩, ERN-EN 00396

៣០៦ ***បីតោន៖*** ដូចឯកសារយោងខាងលើ។ សម្រាប់ការយោងទៅរកស្រូវ សូមមើល ប៉ុល ពត, *របាយការណ៍*, ទំព័រ ១៨៧ និង *មេរៀនសង្ខេប* ទំព័រ ២២០។ ***ពីរតោន៖*** សីហនុ សន្ទរកថាទៅកាន់សភា, ដកស្រង់ក្នុង Massenet to MAE, លេខ 1295/AS, ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៩៦៣ ក្នុង c. CLV 16, QD។ ***ក្នុងខែឧសភា ...អំណាចរដ្ឋ៖*** ប៉ុល ត្រូវបានដកស្រង់ក្នុង អ៊ិន សុភាព ខៀវ សំផន, ទំព័រ ១០៦។ ***នង សួន៖*** នង សួន, ចម្លើយសារភាព, ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៧៧។ ***រដូវក្តៅនោះ៖*** Criddle និង Butt Mam, *បំផ្លាញ,* ទំព័រ ៥០។ Denise Alfonso ក៏បានចងចាំអំពីការត្រូវបានបង្ហាញនូវគម្រូក្រដាសប្រាក់ថ្មី នៅភូមិមួយចម្ងាយប្រមាណ៣០ម៉ាយល៍ខាងត្បូងភ្នំពេញ ប្រហែលក្នុងខែ កក្កដា ឆ្នាំ ១៩៧៥ (De Nike និងអ្នកដទៃ, ទំព័រ ៤៥៣)។ សូមមើលផងដែរ ពេជ្រ ឈាង, ការសម្ភាសន៍, អន្លង់វែង ខែធ្នូ ថ្ងៃទី១០-១១ ឆ្នាំ២០០១ និងឯកសារលេខ ៣, ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៥ ដែលត្រូវបានដកស្រង់ក្នុង Kiernan, *របប,* ទំព័រ ៩៥។

-មេរៀនសង្ខេបស្តីពីប្រវត្តិនៃចលនាបដិវត្តន៍កម្ពុជា ដឹកនាំដោយបក្សកុម្មុយនីស្តកម្ពុជា (គ្មានចុះកាលបរិច្ឆេទប៉ុន្តែនៅដើមឆ្នាំ១៩៧៧) ក្នុង Chandler និងអ្នកដទៃ, *ផែនការ ប៉ុល ពត* (***មេរៀនសង្ខេប***)

[ERN 00396577-00396578]

ប៉ុល ចង់បាននំរបស់គាត់ និងហូបនំនោះ។

គាត់ចង់បានបក្សដ៏ស្អាតសំបរិសុទ្ធដាច់ខាតមួយ ដែលសមាសភាពសង្ស័យទាំងអស់ត្រូវបានដកចេញ ហើយនៅពេលដំណាលគ្នា បង្រួបបង្រួមប្រជាជនទាំងមូលសម្រាប់ការតស៊ូដែលចូលមកដល់ជាមួយវៀតណាម។ គាត់ចង់ឱ្យមនុស្សគ្រប់គ្នាត្រូវបានចិញ្ចឹមបានល្អ ធ្វើការងារក្នុងរយៈពេលសមស្រប និងមានថ្ងៃឈប់សម្រាកចំនួន ៣,៤ ឬ៥ថ្ងៃក្នុងមួយខែ ដើម្បីឱ្យពួកគាត់មានភាព "មុតស្រួច និងក្លៀវក្លា" ប៉ុន្តែនៅពេលដំណាលគ្នានោះ គាត់ទទូចថាគោលដៅបីតោនក្នុងមួយហិកតាត្រូវតែសម្រេចឱ្យបាន ទោះបីជាក្នុងតម្លៃណាក៏ដោយ។

សម្រាប់កម្មាភិបាលដែលត្រូវចាត់ចែងគោលនយោបាយរបស់គាត់ ជម្រើសមានភាពជាក់លាក់។ ធ្វើឱ្យពួកគេភ័យខ្លាច ពួកគាត់បានឆ្លើយតបតាមរយៈការធ្វើឱ្យប្រជាជនភ័យខ្លាចក្រោមការគ្រប់គ្រងរបស់ពួកគាត់។ ក្នុងរដ្ឋមួយដែលសម្រេចថាស្មារតីមនុស្សអាចសម្រេចបានគ្រប់យ៉ាង បរាជ័យគឺជាការបំផ្លិចបំផ្លាញ។ ប្រសិនបើជម្រើសគឺរវាងការលើកកម្ពស់ជីវភាពប្រជាជន-ដូចដែល ប៉ុល បានទទូច-និង ជាលទ្ធផល ខកខានមិនបានបំពេញគោលដៅបក្ស ឬសម្រេចតាមគោលដៅទាំងនោះ-ដូចដែល ប៉ុល ពត បានទទូច-ដោយមិនគិតអំពីជីវភាព មន្ត្រីភាគច្រើនបានពេញចិត្តជម្រើសចុងក្រោយ។ ដោយសារមានការអនុវត្តការហូបរួម និងការហាមឃាត់ការស្វែងរកអាហារ មនុស្សជាច្រើនបានរស់នៅយ៉ាងយ៉ាប់យ៉ឺន។ នៅពេលមានការរុំតបន្តិចបន្តួច អ្វីដែលបន្សល់នៅគឺដំបង។

ចាប់ពីចុងឆ្នាំ១៩៧៦ និងពិសេសចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៧ កម្ពុជារអិលត្រឡប់ទៅក្នុងអរិយធម៌នៃអតីតកាលបុរាណរបស់ខ្លួន។

**ជើងទំព័រ៖**

[ERN 00396721]

៣៧០ ***“សិទ្ធិអំណាចដើម្បីកម្ទេច”៖*** កំណត់ហេតុនៃគណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា, ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦, Dossier D693, មជ្ឈមណ្ឌលឯកសារកម្ពុជា។ ***ប៉ុន៖*** សៀវភៅកត់ត្រាឆ្នាំ ១៩៧៨ ដែលគ្មានចំណងជើងដែលមានបញ្ជីរបស់ ប៉ុន និងទុយ, មជ្ឈមណ្ឌលឯកសារកម្ពុជា។ ***អ្នកទោស...ទៅក្នុងរណ្តៅមួយ៖*** ការសម្ភាសន៍ជាមួយឆ្មាំមន្ទីរ ស-២១ ក្នុងខ្សែភាពយន្តរបស់ រិទ្ធី ប៉ាន់, ស-២១៖ *La Machine de Mort Khmere Rouge, ដូចខាងលើ*។

៣៧០-១ ***យើងបានបញ្ឈប់...ខ្មៅ និងមិនសំខាន់៖*** ហាំង ង៉ោ, *Odyseey,* ទំព័រ ២១៧-១៨ និង ២២២-៣។

[ERN 00396514-00396516]

ការសម្រេចដ៏សំខាន់ដូចគ្នាមួយទៀតត្រូវបានធ្វើដោយក្រុមនោះនាខែនោះ៖ ការមិនប្រើប្រាស់លុយ។

មួយឆ្នាំមុន នៅខែមាឃ គណៈកម្មាធិការមជ្ឈិមបានឯកភាពថារូបិយប័ណ្ណថ្មីដែលបានបោះពុម្ពនៅចិនគួរត្រូវបានចេញឲ្យបានឆាប់របស័តាមដែលអាចធ្វើទៅបានក្រោយពេលបែកភ្នំពេញ។

ប៉ុន្តែនៅពេលនោះ មេដឹកនាំ ប.ក.ក ដ៏មានឥទ្ធិពលមួយចំនួនបានចោទសួរអំពីភាពវៃឆ្លាតនៃវិធានការទាំងនេះ។ ជំនួយការរបស់ ប៉ុល ឈ្មោះ ភី ភួន បានចងចាំអំពីការប្រជុំក្រៅផ្លូវការរបស់គណៈកម្មាធិការអចិន្ត្រៃយ៍នៅវត្តប្រាក់ក្នុងចុងខែសីហា ដែលនៅទីនោះ ម៉ុក បាននិយាយប្រឆាំងការប្រើប្រាស់លុយ៖

> ម៉ុក ស្រឡាញ់ប្រព័ន្ធដោះដូរ។ គាត់បាននិយាយថាតំបន់ខ្លះសម្បូរស្រូវ តំបន់ខ្លះមានផលិតផលផ្សេង។ ចម្លើយគឺប្រព័ន្ធដោះដូរ។ គាត់បាននិយាយផងដែរថាប្រសិនបើគ្មានលុយ វានឹងដកចេញនូវបញ្ហានៃអំពើពុករលួយ និងកាត់បន្ថយសកម្មភាពនៃភ្នាក់ងារខ្មាំង។ គាត់បាននិយាយថា “នៅពេលរបួសមិនទាន់ជាសះស្បើយ” “អ្នកមិនគួរយកឈើផ្គិះវាឡើយ។ អ្នកត្រូវទុករបួសនោះមួយឡែក បើមិនដូច្នោះ វានឹងកាន់តែយ៉ាប់យ៉ឺន”។ សោម ភីម និង កុយ ធួន បានគាំទ្រគាត់។ ពួកគាត់បានឯកភាពជាមួយទស្សនៈរបស់ម៉ុក។

ប៉ុល បានយល់ឃើញថាទឡ្ហីករណ៍របស់ ម៉ុក មានភាពគួរឲ្យជឿជាក់។ ក្រៅពីការពិចារណាជាក់ស្តែង- “កង្វះបទពិសោធន៍” នៃរបបនេះ ដូចដែលគាត់បាននិយាយ ការយោងទៅរកការលំបាកនៃការប្រែក្លាយយុវជនពាក់កណ្តាលអនក្ខរកម្ម ដែលមានដើមកំណើតជាកសិករក្រីក្រ និងត្រឹមត្រូវផ្នែកនយោបាយ ឲ្យក្លាយជាអ្នកធ្វើការ

ធនាគារដ៏មានសមត្ថភាព- មានហេតុផលមនោគមន៍វិទ្យាសំខាន់ជាងនេះទៀត។ បញ្ហាថាតើត្រូវប្រើប្រាស់លុយឬយ៉ាងណា គាត់បានប្រាប់ទៅគណៈកម្មាធិការមជ្ឈិមថា វាពាក់ព័ន្ធទៅនឹងមូលដ្ឋាននៃរដ្ឋខ្មែរក្រហម៖

> រដ្ឋជាអង្គការមួយដែលគោលបំណងរបស់វាគឺដើម្បីរក្សាសិទ្ធិអំណាចរបស់វណ្ណៈមួយតាមរយៈការអនុវត្តអំណាចផ្តាច់ការទៅលើវណ្ណៈដទៃលើគ្រប់ផ្នែកទាំងអស់...ប៉ុន្តែរដ្ឋក៏ជាឧបករណ៍មួយដែលបង្កើតវណ្ណៈសង្គមមួយដែលមានអភ័យឯកសិទ្ធិដែលនៅពេលវាវិវត្តន៍ កាត់ផ្តាច់ពីវណ្ណៈអធន និងពីវណ្ណៈកម្មករ។ នេះបានកើតឡើង ជាឧទាហរណ៍ នៅសហភាពសូវៀត...និង [ក្នុងវិសាលភាពខ្លះ] នៅកូរ៉េ [ខាងជើង] និងនៅ ចិន។ ស្របតាមគោលការណ៍ម៉ាក្សលេនីន មានការចាំបាច់ដើម្បី...កាត់បន្ថយជាបន្តបន្ទាប់នូវវិការៈនេះដែលជារដ្ឋ រហូតដល់វាត្រូវបានពន្លត់ទាំងស្រុង ដោយផ្តល់ទីកន្លែងទៅឲ្យ [ប្រព័ន្ធនៃ] ការគ្រប់គ្រងដោយខ្លួនឯងនូវរោងចក្រពីសំណាក់វណ្ណៈអធន និងកសិកម្មដោយកសិករ។ វណ្ណៈខ្ពស់ដែលមានអភ័យឯកសិទ្ធិនឹងបន្ទាប់មកបាត់ខ្លួនព្រមគ្នា។
>
> រហូតមកទល់នឹងពេលបច្ចុប្បន្ន ការពិតដែលថាយើងមិនប្រើប្រាស់លុយ បានកាត់បន្ថយយ៉ាងច្រើននូវទ្រព្យសម្បត្តិឯកជន និងបានលើកកម្ពស់ទំនោរទូទៅទៅរកសមូហភាព។ ប្រសិនបើយើងចាប់ផ្តើមប្រើប្រាស់លុយម្តងទៀត វានឹងនាំត្រឡប់មកវិញនូវមនោសញ្ចេតនានៃទ្រព្យសម្បត្តិឯកជន និងរុញច្រានបុគ្គលម្នាក់ៗពីសមូហភាព។ លុយជាឧបករណ៍បង្កើតអភ័យឯកសិទ្ធិនិងអំណាច។ អ្នកដែលមានលុយអាចប្រើប្រាស់វាដើម្បីសូកប៉ាន់កម្មាភិបាល...[និង] កម្ទេចប្រព័ន្ធរបស់យើង។ ប្រសិនបើយើងអនុញ្ញាតឲ្យមនោសញ្ចេតនានៃទ្រព្យសម្បត្តិឯកជនរីកធំធាត់ បន្តិចម្តងគំនិតរបស់ប្រជាជននឹងងាកទៅរកតែការបង្កើនទ្រព្យសម្បត្តិឯកជន...ប្រសិនបើយើងយកផ្លូវនោះ បន្ទាប់មកក្នុងរយៈពេលមួយឆ្នាំ ឬដប់ឬម្ភៃឆ្នាំ តើសង្គមកម្ពុជារបស់យើងដែលបច្ចុប្បន្នស្អាតស្អំយ៉ាងនេះ នឹងប្រែក្លាយទៅជាយ៉ាងណា?
>
> លុយជាគ្រោះថ្នាក់ ទាំងនៅក្នុងបច្ចុប្បន្ននិងអនាគត។ យើងមិនត្រូវប្រញាប់ប្រើប្រាស់វានោះឡើយ...យើងចាំបាច់គិតឲ្យកាន់តែស៊ីជម្រៅអំពីបញ្ហានេះ។

នៅថ្ងៃទី ១៩ ខែ កញ្ញា សន្និបាតបានសម្រេចមិនចេញផ្សាយក្រដាស់រូបិយប័ណ្ណថ្មីនេះឡើយ ដែលជាការសម្រេចមួយដែលត្រូវបានបញ្ជាក់នៅឯសមាជលើកទីបួននៃបក្សកុម្មុយនីស្តកម្ពុជានៅបួនខែបន្ទាប់។ ការផ្គត់ផ្គង់រូបិយប័ណ្ណដែលត្រូវបានចែកចាយរួចហើយនោះ ត្រូវបានប្រមូលទុកក្នុងឃ្លាំងនៅភ្នំពេញ។



Translated: [00396488-00396489]; [00396491]; [00396530]; [00396497-00396499]; [00396713-00396714]; [00396501-00396502]; [00396503-00396504]; [00396508-00396509]; [00396425]; [00396536]; [00396513]; [00396514]; [00396577-00396578]; [00396721]; [00396514-00396516]; [00396552-00396553]; [00396528]; [00396529]; [00396530]; [00396554]; [00396555]; [00396556]; [00396560]

ជើងទំព័រ

៣០៦ ***បីគោន៖*** ដូចឯកសារយោងខាងលើ។ សម្រាប់ការយោងទៅរកស្រូវ សូមមើល ប៉ុល ពត, *របាយការណ៍*, ទំព័រ ១៨៧ និង *មេរៀនសង្ខេប* ទំព័រ ២២០។ ***ពីរតោន៖*** សីហនុ សន្ទរកថាទៅកាន់សភា, ដកស្រង់ក្នុង Massenet to MAE, លេខ 1295/AS, ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៩៦៣ ក្នុង c. CLV 16, QD។ ***ក្នុងខែ ឧសភា ...អំណាចរដ្ឋ៖*** ប៉ុល ត្រូវបានដកស្រង់ក្នុង អ៊ិន សុភាព ខៀវ សំផន, ទំព័រ ១០៦។ ***នង សួន៖*** នង សួន, ចម្លើយសារភាព, ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៧៧។ ***វង្វេងក្តៅនោះ៖*** Criddle និង Butt Mam, *បំផ្លាញ,* ទំព័រ ៥០។ Denise Alfonso ក៏បានចងចាំអំពីការត្រូវបានបង្ហាញនូវគម្រូក្រដាសប្រាក់ថ្មី នៅភូមិមួយចម្ងាយប្រមាណ៣០ម៉ាយល៍ខាងត្បូងភ្នំពេញ ប្រហែលក្នុងខែ កក្កដា ឆ្នាំ ១៩៧៥ (De Nike និងអ្នកដទៃ, ទំព័រ ៤៤៣)។ សូមមើលផងដែរ ពេជ្រ ឈាង, ការសម្ភាសន៍, អន្លង់វែង ខែធ្នូ ថ្ងៃទី១០-១១ ឆ្នាំ២០០១ និងឯកសារលេខ ៣, ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៥ ដែលត្រូវបានដកស្រង់ក្នុង Kiernan, *របប,* ទំព័រ ៩៤។

៣០៧ ***ម៉ុក បានពេញចិត្ត... ទស្សនៈ៖*** ភី ភួន, កិច្ចសម្ភាសន៍។ ***រដ្ឋ...បញ្ហានេះ៖*** អ៊ិន សុភាព, *ខៀវ សំផន*។

៣០៨ ***ថ្ងៃទី ១៩ ខែ កញ្ញា៖*** ឯកសារលេខ ៣, ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៥, សម្រង់ក្នុង Kiernan, *របប,* ទំព័រ ៩៩។ ឡូរ៉ង់ ពិក ត្រូវបានប្រាប់នៅពេលគាត់បានមកដល់ភ្នំពេញក្នុងខែតុលាឆ្នាំ១៩៧៥ថា "លុយត្រូវបានលុបបំបាត់" (*Horizon,* ទំព័រ ១១)។

[ERN 00396552-00396553]

ដំណាក់កាលដំបូងនៃបដិវត្តន៍សង្គមនិយម ដែលបានចាប់ផ្តើមក្នុងខែ មេសា ឆ្នាំ ១៩៧៥ បានឃើញការបង្កើតសហករណ៍ថ្នាក់ភូមិនៅទូទាំងប្រទេស។ ក្នុងខែតុលា គណៈកម្មាធិការអចិន្ត្រៃយ៍បានឯកភាពបោះជំហានលើដំណើរការនេះមួយជំហានទៀត។ ភូមិមួយចំនួននាពេលនេះត្រូវបាននឹងត្រូវបានភ្ជាប់ទំនាក់ទំនងក្នុងសហករណ៍មួយដែលមានមនុស្សចំនួន៥០០ ឬមួយពាន់គ្រួសារ ដោយមានគោលដៅចុងក្រោយគឺបង្កើតអង្គភាពខ្នាតឃុំដែលមានចំនួនប្រជាជនច្រើនជាងនោះពីរដង។ នៅពេលជាមួយគ្នានោះ រោងបាយហូបរួមត្រូវបានរៀបចំ។ ក្នុងការអនុវត្ត "ការហូបរួម" ដូចដែលខ្មែរក្រហមបានហៅនោះ មានន័យថាគ្រួសារនីមួយៗត្រូវបោះបង់ឆ្នាំងបាយនិងចានបាយរបស់ខ្លួន ដោយទុកតែកំសៀវដាំទឹកនិងស្លាបព្រាមួយសម្រាប់សមាជិកគ្រួសារម្នាក់ៗ។ តាម

ប៉ែកនានានៃភូមិភាគខាងជើង និងភូមិភាគពាយ័ព្យ ប្រព័ន្ធថ្មីនេះបានចូលជាធរមានពីខែធ្នូ ឆ្នាំ១៩៧៥។ នៅកន្លែងផ្សេង ពិសេសនៅតាមប៉ែកនានានៃភូមិភាគបូព៌ា ការហូបជាគ្រួសារបានបន្តរហូតដល់ពាក់កណ្ដាលឆ្នាំ១៩៧៧។ ជួនកាល ស្រុកជិតខាងបានអនុវត្តវិធានថ្មីទាំងនេះ ខុសគ្នារាប់ខែ។ អ្នកភូមិដែលត្រូវបានបង្ខំឱ្យហូបរួមនៅត្រើយម្ខាងនៃផ្លូវជាតិ បានមើលដោយក្ដីច្រណែនឃើញអ្នកជិតខាងរបស់ពួកគាត់នៅត្រើយម្ខាងទៀតនៃផ្លូវ កំពុងដាំស្លអាហារពេលយប់នៅខាងក្រៅខ្ទមរបស់ពួកគាត់។ ដូចភាគច្រើននៅក្នុងរបបខ្មែរក្រហមនៅកម្ពុជា វាហាក់ដូចជាអាស្រ័យទៅលើចិត្តរបស់កម្មាភិបាលមូលដ្ឋាន។

ការហូបរួមបានប្រែក្លាយយ៉ាងរហ័សទៅជាទិដ្ឋភាពមួយក្នុងចំណោមទិដ្ឋភាពដែលត្រូវបានស្អប់ខ្ពើមនៃការរស់នៅក្រោមរបបខ្មែរក្រហម។

តាមទ្រឹស្ដី វាបានធ្វើឱ្យអ្វីៗគ្រប់យ៉ាងងាយស្រួលជាងមុន។ ធីរិទ្ធ ប្រពន្ធរបស់ អៀង សារី បាននិយាយថា "ពួកគាត់មិនចាំបាច់ដាំស្ល"។ "ពួកគាត់គ្រាន់តែធ្វើការងារ ហើយបន្ទាប់មកពួកគាត់ត្រឡប់មកញ៉ាំ"។ ហើយអ្នកខ្លះបានយល់ឃើញដូច្នោះដែរ។ ឡូរ៉ង់ ពិក នៅមន្ទីរ ប១ បានមានអារម្មណ៍ថាទោះបីមិនឯកភាពក្នុងលក្ខណៈផ្ទាល់ខ្លួនយ៉ាងណាក៏ដោយចុះ ក៏ការហូបរួមមានគុណសម្បត្តិជាក់ស្ដែងដ៏ត្រចង់។ គ្រួសារខ្មែរកាត់ចិនខ្លះដែលមិនដឹងចិញ្ចឹមខ្លួនយ៉ាងដូចម្ដេចនៅជនបទ បានយល់ឃើញថាវាមិនសូវចោទជាបញ្ហាឡើយ។ ប៉ុន្តែមនុស្សផ្សេងទៀតបានស្អប់វា។ ការផ្គត់ផ្គង់អាហារបានធ្លាក់ចុះយ៉ាងគំហុក ពីព្រោះចុងភៅបានលួចមួយចំណែកសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ឬសម្រាប់ប្រធានភូមិ។ ទំនាក់ទំនងគ្រួសារ ដែលស្ថិតក្រោមសំពាធរួចទៅហើយត្រូវបានធ្វើឱ្យទន់ខ្សោយបន្ថែមទៀត។ ពិសេស ស្ត្រីបានមានអារម្មណ៍ថាវាបានប៉ះពាល់តួនាទីជាប្រពៃណីរបស់ពួកគាត់។ "ប្រជាជនមូលដ្ឋាន" បានបាត់បង់អភ័យឯកសិទ្ធិរបស់ពួកគាត់។ ពួកគាត់លែងអាចចិញ្ចឹមជីវិតជាមួយដំណាំផ្លែឈើ និងចម្ការបន្លែក្បែរផ្ទះទៀតហើយ ពីព្រោះនៅពេលនេះដូចអ្វីគ្រប់យ៉ាងទៀតដែរ ទាំងអស់នេះត្រូវបានដាក់ជាកម្មសិទ្ធិរួម។ រទេះនិងគោរបស់ពួកគាត់ត្រូវបានរិបអូស។ ដូចគ្នានេះចំពោះស្តុកគ្រាប់ធញ្ញជាតិ មង កង់ និងអ្វីផ្សេងទៀតដែលអាចដាក់ឱ្យមនុស្សម្នាក់ៗនៅដាច់ដោយឡែកពីសមូហភាព។ នៅតាមភូមិជាច្រើន ផ្ទះធំៗ-ដែលរមែងជាកម្មសិទ្ធិរបស់ "ប្រជាជនមូលដ្ឋាន" ត្រូវបានរុះរើដើម្បីយកឈើសម្រាប់រោងបាយថ្មី និងធ្វើខ្ទមតូចៗដែលតូចស្ទើរតែមិនអាចគេងបាន ដែលត្រូវបានសាងសង់នៅទីកន្លែងរបស់ពួកគាត់។

ការហូបបួមទោះជាដើម្បីក្នុងចេតនាជាសមភាពបំផុតនៃគោលនយោបាយ ក្នុងការអនុវត្ត រិតតែធ្វើឲ្យការបែងចែកកាន់តែខ្លាំងរវាង “អ្នកមាន” និង “អ្នកអត់” នៃសង្គមថ្មីនេះ។ ប៉ុល ពត អាចរិះគន់ “អំណាចផ្តាច់ការនិយម ការអួតអាង ការសំញែង ការងារធំ និង “ការធ្វើខ្លួនដូចព្រះទៅលើប្រជាជន” ប៉ុន្តែនៅពេលដែលចរន្តនៃការធ្វើមូលវិវដ្តនិយម បានកើនឡើង បាតុភូតទាំងនេះបានកើនឡើងផងដែរ។

នៅឯជនបទ អ្នកមានអំណាច-ឈ្លប ទាហាន មន្ត្រីឃុំ និងមន្ត្រីស្រុក ហូបដាច់ដោយឡែក និងហូបឆ្អាញ់។ ខ្លះមានអាហារ៤ពេលក្នុងមួយថ្ងៃ និងមានចុងភៅផ្ទាល់ខ្លួនដើម្បីរៀបចំម្ហូបដែលពួកគាត់ចូលចិត្ត។ កម្មករផ្លូវរថភ្លើង និងក្រុមដែលមានអភ័យឯកសិទ្ធិដទៃទៀតត្រូវបានផ្តល់ឲ្យនូវរបបពិសេសនៃសាច់ និងអង្ករ។ នៅឯក្រសួងការបរទេស មន្ត្រីជាន់ខ្ពស់ក៏បានផលប្រយោជន៍ពីរបបដាច់ដោយឡែកមួយ។

ហេតុអ្វីជនកុម្មុយនីស្តកម្ពុជាបង្កើតប្រព័ន្ធបែបនេះ?

ចេតនាគឺពុំមែនសងសឹកក្រុម ឬវណ្ណៈណាមួយឡើយ ពីព្រោះបើទោះបីជាភាពគុំគួនរបស់កម្មាភិបាលម្នាក់ៗ បានប៉ះពាល់ដល់វិធីនៃការអនុវត្តគោលនយោបាយក៏ដោយ ក៏ការបែងចែកវណ្ណៈសង្គមក្រោមរបបខ្មែរក្រហមមានភាពរលូនតាមទ្រឹស្តី។

ពីឆ្នាំ១៩៧៥ តរៀងមក មនុស្សទាំងឡាយដែលរស់នៅក្នុងសហករណ៍ចុងកាត់មាត់ញក និយាយម្យ៉ាងទៀតគឺប្រជាជនស្ទើរតែទាំងអស់ ត្រូវបានកំណត់ប្រភេទជាបីក្រុម៖ សមាជិកពេញសិទ្ធិ បេក្ខជន និងបញ្ញើក្អែក។ មនុស្សប្រភេទទីមួយជាទូទៅគឺកសិករក្រីក្រ និងកសិករថ្នាក់ក្រោមកណ្តាល ហើយមានសិទ្ធិទទួលរបបអាហារពេញលេញ មានមុខនាទីនយោបាយក្នុងសហករណ៍ ចូលកងទ័ព និងដាក់ពាក្យចូលជាសមាជិកបក្ស។ បេក្ខជន មានរបបអាហារពេញលេញ និងអាចមានតំណែងរដ្ឋបាលថ្នាក់ក្រោម។ បញ្ញើក្អែក “ស្ថិតនៅចុងក្រោយនៃបញ្ជីចែកចាយរបបអាហារ ស្ថិតនៅទីមួយក្នុងបញ្ជីសម្លាប់ និងគ្មានសិទ្ធិនយោបាយ”។ ជាដំបូងមនុស្សពីរប្រភេទខាងដើម ជា “ប្រជាជនមូលដ្ឋាន” ដែលបានរស់នៅក្នុង “តំបន់រំដោះ” មុនពេលជ័យជម្នះរបស់ពួកកុម្មុយនីស្ត ចំណែកអ្នកត្រូវបាននិរទេសពីទីក្រុង ឬ “ប្រជាជនថ្មី” ទាំងអស់បានក្លាយជាជនបញ្ញើក្អែក។ ឋានៈពីមុនក៏បានដើរតួនាទីមួយផ្នែក ហើយក្នុងករណីជាច្រើន អតីតកសិករធូធារ ត្រូវបានដាក់ក្នុងក្រុមជាមួយ “ប្រជាជនថ្មី” ក្នុងប្រភេទទាបបំផុត។ ប៉ុន្តែប្រជាជនប្រភេទចុងក្រោយនេះ ក្នុងទ្រឹស្តី ក្លាយជាបេក្ខជន

ហើយពួកគាត់ជាបន្តបន្ទាប់អាចក្លាយជាសមាជិកពេញសិទ្ធិ ប្រសិនបើពួកគាត់បានបង្ហាញអំពីទឹកចិត្តសមស្រប សម្រាប់បុព្វហេតុបដិវត្តន៍។

ក្នុងការអនុវត្ត ការបែងចែកវណ្ណៈជាបីថ្មីនេះត្រូវបានអនុវត្តដោយស្មើភាពឡើយ-ក្នុងតំបន់ខ្លះ វាបានចូលជាធរមានរួចទៅហើយក្នុងឆ្នាំ១៩៧៥ ចំណែកតំបន់ខ្លះទៀតរហូតទាល់តែឆ្នាំ១៩៧៧ ឬក្រោយមកទៀត-ហើយការបែងចែកជាប្រជាជនជាពីរប្រភេទជាមូលដ្ឋាននៅតែមានរវាង ប្រជាជន “មូលដ្ឋាន” និងប្រជាជន “ថ្មី”។ ភាពខុសគ្នានៃឋានៈរវាងក្រុមទាំងពីរនេះ មានភាពធំធេង ពិសេសក្នុងឆ្នាំដំបូងនៃរបបខ្មែរក្រហម។ “ប្រជាជនមូលដ្ឋាន” អាចដាំដុះដើម្បីបរិភោគផ្ទាល់ខ្លួនដើម្បីបន្ថែមពីលើរបបហូបរួម ហើយប្រសិនបើពួកគាត់ល្មើសវិន័យបដិវត្តន៍ រមែងត្រូវបានលើកលែងទោស ឬត្រូវបានគេជឿថាមិនបានធ្វើអ្វីខុសទេ។ ផ្ទុយមកវិញ “ប្រជាជនថ្មី” ជានិច្ចកាលត្រូវបានគេសង្ស័យអាក្រក់បំផុត។ ប៉ុល ខ្លួនឯងផ្ទាល់ បានជំរុញឲ្យកម្មាភិបាលមូលដ្ឋានបែងចែកដោយប្រុងប្រយ័ត្ន រវាង “ការប្រព្រឹត្តចំពោះមនុស្សគ្រប់គ្នាដោយឥតរើសអើង ដោយមិនគិតអំពីតួនាទី គោលការណ៍ និងទស្សនៈរបស់បក្ស” និង “ការចាត់ទុកប្រជាជនថ្មីទាំងអស់ជាខ្មាំង”។ ប៉ុន្តែនោះជាការទាមទារហួសហេតុពីកសិករដែលមានការសិក្សាទាបដែលជារដ្ឋបាលភូមិ។ នៅតាមតំបន់ជាច្រើន “ប្រជាជនថ្មី” នៅតែបន្តត្រូវបានចាត់ទុកជា “ឈ្លើយសឹក” ដូចដែលពួកគាត់ធ្លាប់ត្រូវបានចាត់ទុកក្នុងអំឡុងពេលជម្លោះ។ មិនជាអ្វីគួរឲ្យភ្ញាក់ផ្អើលឡើយ មនុស្សភាគច្រើនបានសន្និដ្ឋានថាប្រព័ន្ធនេះត្រូវបានរៀបចំឡើងដោយចេតនាដើម្បីសម្លាប់រង្គាលពួកគាត់ ដោយបន្សល់ទុកតែ “ប្រជាជនមូលដ្ឋាន” ដែលជាវណ្ណៈតែមួយគត់របស់ប្រទេសនេះ។ តាមការពិត នោះពុំមែនជាចេតនាសោះឡើយ។ អ្វីដែលបានកើតឡើងគឺជាការខកខាននៃការបំពេញមុខងារនៃគោលនយោបាយខ្មែរក្រហម ដែលមួយក្នុងចំណោមជាច្រើនបានរារាំងការអនុវត្តចក្ខុវិស័យរបស់ ប៉ុល នៃពេលអនាគត និងដែលចាំបាច់សម្រាប់គោលនយោបាយនោះ ពីព្រោះពួកវាបានកើតចេញពីភាពមិនស៊ីសង្វាក់ជាសារវ័ន្តរវាងចក្ខុវិស័យ និងការពិតនៅកម្ពុជា។

ជើងទំព័រ៖

២៩២- **“សិទ្ធិនយោបាយ...ចុងក្រោយ”**៖ Heder, *ការកាន់កាប់,* ទំព័រ ៦; Ebihara, *បដិវត្តន៍ និងការកែប្រែឡើងវិញ,* ទំព័រ ២៥។

ប្រភព៖



Translated: [00396488-00396489]; [00396491]; [00396530]; [00396497-00396499]; [00396713-00396714]; [00396501-00396502]; [00396503-00396504]; [00396508-00396509]; [00396425]; [00396536]; [00396513]; [00396514]; [00396577-00396578]; [00396721]; [00396514-00396516]; [00396552-00396553]; [00396528]; [00396529]; [00396530]; [00396554]; [00396555]; [00396556]; [00396560]

Heder, Stephen, *ការកាន់កាប់កម្ពុជា និងការតស៊ូ,* សាកលវិទ្យាល័យចុឡាឡុងកន, វិទ្យាស្ថានសិក្សាអាស៊ី, បាងកក, ១៩៨០ (*ការកាន់កាប់*)

[ERN: 00396528]

ការឃ្លានគឺជាអាវុធនៅជនបទ មិនចាញ់នៅក្នុងជំរំលត់ដំឡើយ។ ពាក្យស្លោករបស់ លេនីន “អ្នកមិនធ្វើការ មិនហូប” ត្រូវបានអនុវត្តចំៗនៅតាមបណ្តាសហករណ៍នានានៅកម្ពុជា ដែលពួករុស្ស៊ីមិនដែលបានសុបិន្តឃើញ។ នៅក្នុងតំបន់យ៉ាប់យ៉ឺន ការងារមួយថ្ងៃ បានទឹកបបរវារមួយចាន។ អ្នកណាឈឺមិនអាចធ្វើការងារបានមិនបានទទួលអ្វីឡើយ។ ជារឿយៗ ជំងឺមានន័យស្មើទៅនឹងការប្រឆាំងនឹងរបបនេះ ឬយ៉ាងហោចណាស់ជាកង្វះ “ស្មារតីបដិវត្តន៍” ដែលត្រូវបានចាត់ទុកថាស្មើរតែមិនល្អដូចជំងឺដែរ ហើយគ្លីនិកនៅតាមតំបន់ចុងកាត់មាត់ញក ដែលគិលានុប្បដ្ឋយិការដែលមិនបានទទួលការបណ្តុះបណ្តាល បានចែកថ្នាំបុរាណ គឺមិនលើសពីកន្លែងទុកសាកសពឡើយ។

ប៉ុន្តែការស្រែកឃ្លាន ផ្គួបនឹងការថែទាំសុខភាពដែលគ្មានអត្ថិភាព គឺជាកាំបិតមុខពីរ។

សម្រាប់កម្មាភិបាលមូលដ្ឋាន អាហារជាមធ្យោបាយចាំបាច់នៃការគ្រប់គ្រង ដែលត្រូវបានកំណត់ដោយការប្រព្រឹត្តិខុសពីគ្នាទៅលើប្រជាជន “ថ្មី” និងប្រជាជន “មូលដ្ឋាន”។ សម្រាប់ប្រជាជន “មូលដ្ឋាន” ជីវិតអាចទ្រាំទ្របាន។ ការលំបាករបស់ “ប្រជាជនថ្មី” គឺជាការក្រើនរម្លឹកជាប់ជាប្រចាំមួយចំពោះពួកគាត់អំពីភ័ព្វសំណាងរបស់ពួកគាត់ ដែលត្រូវបានរៀបចំឡើងដើម្បីជំរុញឲ្យពួកគាត់ខំប្រឹងធ្វើការងារដើម្បីកសាងខ្លួនជាថ្មី សំដៅវិវត្តន៍ខ្លួនពីជនបញ្ញើក្អែកទៅជាបេក្ខជន ឬជនពេញសិទ្ធិដែលមានរបបអាហារកើនឡើងទៅតាមនោះ។ យ៉ាងហោចណាស់ នោះជាទ្រឹស្តី។ ក្នុងការអនុវត្ត វាកម្រធ្វើទៅតាមវិធីនោះណាស់។ ប្រព័ន្ធខ្មែរក្រហមជាប្រព័ន្ធចាប់បង្ខំជាមូលដ្ឋាន។ ប៉ុន្តែនៅពេលដំណាលគ្នានោះ មានការខ្វះខាតពិតប្រាកដមួយ។ សូម្បីតែជាមួយអង្ករជំនួយពីចិន ជង្រុកស្រូវក្រោយសង្គ្រាមមានតិចគួរឲ្យគ្រោះថ្នាក់។ នៅពេល “ប្រជាជនថ្មី” បានអត់ឃ្លានរហូតដល់ស្លាប់នៅរដូវរំហើយនោះ វាពុំមែនជាបញ្ហានៃគោលនយោបាយទេ ប៉ុន្តែគឺដោយសារប្រព័ន្ធនោះខកខានមិនដំណើរការ។



Translated: [00396488-00396489]; [00396491]; [00396530]; [00396497-00396499]; [00396713-00396714]; [00396501-00396502]; [00396503-00396504]; [00396508-00396509]; [00396425]; [00396536]; [00396513]; [00396514]; [00396577-00396578]; [00396721]; [00396514-00396516]; [00396552-00396553]; [00396528]; [00396529]; [00396530]; [00396554]; [00396555]; [00396556]; [00396560]

ប៉ុល ចង់បានប្រជាជនច្រើនជាងនេះ មិនមែនប្រជាជនតិចជាងនេះទេ។ គាត់បានអំពាវនាវឲ្យបង្កើនចំនួនប្រជាជនឲ្យបានចំនួនទ្វេរដង ឬចំនួនបីដង រហូតដល់ "១៥ ឬ ២០ លានក្នុងរយៈពេល ១០ ឆ្នាំ" ដើម្បីអនុវត្តផែនការរបស់គាត់ក្នុងការធ្វើឲ្យកម្ពុជារុងរឿងរឹងមាំ។

[ERN 00396529]

ប៉ុន្តែនៅក្នុងគោលនយោបាយមានបង្កប់រួចទៅហើយនូវចំណុចខ្វែងគ្នាមួយចំនួន ។ នៅក្នុងអំឡុងពេលដែលជួបគ្រោះទុរភិក្សជាទូទៅ បណ្ដាកម្មាភិបាលត្រូវរំពឹងថា ធានាឲ្យមានអាហារអប្បបរិមា ដែលមានសុខភាពគ្រប់គ្រាន់សម្រាប់ប្រជាជនទាំងអស់ ខណៈដែលត្រូវរក្សានូវឋានានុក្រមនៃរបបអាហាររវាងប្រជាជន "ថ្មី" និងប្រជាជន "ចាស់" ។ នេះមានន័យថា ត្រូវធានាថា អ្នកដែលនៅក្នុងតួនាទីទទួលខុសត្រូវទាំងឡាយដែលរស់នៅដោយឡែកពីមហាជន-ប្រធានសហករណ៍ និងគណៈស្រុក យោធា កងឈ្លប និងក្រុមផ្សេងៗទៀត ដែលមានបុព្វសិទ្ធិ ដូចជាកម្មកររថភ្លើង ដែលភាពស្មោះត្រង់របស់កម្មករទាំងនេះមានសារៈសំខាន់ចំពោះរបបនោះ-ត្រូវបានផ្ដល់អាហារមិនត្រឹមតែគ្រប់គ្រាន់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាអាហារល្អៗមានសាច់ ឬត្រី បន្ថែមទៅលើបាយ ។ ប៉ុន្តែក្នុងពេលជាមួយគ្នានោះ ការប្រើប្រាស់ភាពអត់ឃ្លានជាធម្យោបាយនៃការដាក់វិន័យ ក៏បាននៅតែអនុវត្ត ដោយសារមិនឃើញមានជម្រើសណាអាចធ្វើទៅកើតផ្សេងពីនេះតាមជាក់ស្ដែង ។

ទាំងនេះមានលក្ខណៈស្របគ្នាទៅនឹងភាពចាំបាច់ជាច្រើនដែលមិនស៊ីសង្វាក់គ្នាត្រង់ថា កម្មាភិបាលភាគច្រើនបានជ្រើសយកដំណោះស្រាយយ៉ាងសាមញ្ញជាងគេ ៖ កម្មាភិបាលទាំងនោះ និងប្រជាជន "មូលដ្ឋាន" បានហូបអាហារល្អគ្រប់គ្រាន់ ។ ប្រជាជន "ថ្មី" មិនបានហូបអាហារល្អ ខ្វះខាត ។ ភាពអត់ឃ្លាននៅតែជាសម្រាប់ជាមធ្យោបាយដាក់ទណ្ឌកម្ម ។ មនុស្សស្លាប់បណ្ដាលមកពីការខ្វះជីវជាតិ និងជំងឺផ្សេងៗពាក់ព័ន្ធ នៅតែមានអាត្រាខ្ពស់ ហើយសុខភាពនិងកម្លាំងរបស់ប្រជាជន "ថ្មី" នៅតែបន្តធ្លាក់ដុនដាបទៅៗ ។

មានបញ្ហាប្រហាក់ប្រហែលមួយដែរត្រង់ថា តើប្រជាជនគួរធ្វើការធ្ងន់ប៉ុនណា ហើយ "អំពើហិង្សាធ្ងន់ធ្ងរបំផុតនោះ" ធ្ងន់ដល់កម្រិតណាដែលគួរតែប្រើសម្រាប់ឲ្យប្រជាជនធ្វើការងារធ្ងន់ទាំងនោះ ។

គណៈអចិន្ត្រៃយ៍បានដាក់ចេញនូវការអនុញ្ញាតឲ្យឈប់សម្រាកមួយថ្ងៃនៅក្នុងរាល់១០ថ្ងៃម្ដង-ដែលជាប្រព័ន្ធមួយចម្លងមកពីបដិវត្តបារាំង-ហើយសរុបទៅដល់១៥ថ្ងៃ ជាថ្ងៃសម្រាកក្នុង១ឆ្នាំ ។ ប៉ុល បានពន្យល់ថា

“មិនមានអាហារគ្រប់គ្រាន់សម្រាប់ឲ្យមនុស្សធ្វើការរហូតនោះទេ” ។ “ប្រសិនបើមនុស្សម្នាក់មិនបានសម្រាក គាត់នឹងធ្លាក់ខ្លួនឈឺ ។ មានគោលដៅយុទ្ធសាស្ត្រមួយគឺត្រូវបង្កើនកម្លាំងប្រជាជន ។ អាស្រ័យហេតុនេះការឈប់សម្រាកលំហែកាយត្រូវតែកំណត់ថា ជាកត្តាសំខាន់ជាមូលដ្ឋាន” ។ ប៉ុន្តែ ជាក់ស្តែងថ្ងៃដែលត្រូវឈប់សម្រាកនោះ នៅពេលដែលបានទទួល ត្រូវបានយកទៅប្រជុំនយោបាយ ហើយថ្ងៃឈប់សម្រាកប្រចាំឆ្នាំដែលបានស្នើឡើងនោះ មិនដែលបានអនុវត្តឡើយ ។

ដូច្នោះបញ្ហាបន្ទាប់គឺ កូតាការងារប្រចាំថ្ងៃ ។

ប្រសិនបើកូតាខ្ពស់ពេក អ្នកដែលមិនអាចបំពេញកូតានោះបាននឹងត្រូវទទួលទណ្ឌកម្ម ។

បកប្រែ ៖ [ERN 00396529]

[ERN 00396530]

តាមរយៈការទទួលការងារបន្ថែម ឬអាហារតិចជាងមុន ឬទាំងពីរមុខ ដែលជាញឹកញាប់នាំឲ្យធ្លាក់ខ្លួនឈឺ ឬស្លាប់តែម្តង បានកំណត់តំបន់ និងភាគ។ ប៉ុន្តែបើដាក់កូតាទាប ទិសដៅដែល នឹងមិនអាចសម្រេចបានឡើយ។ ព្យាយាមធ្វើ។ មេដឹកនាំខ្លះ ដោះស្រាយនូវបញ្ហានេះតាមមធ្យោបាយផ្សេងៗដឹកនាំនៅថ្នាក់មូលដ្ឋាន បានប្រធានមួយស្រុកនៅជាពិសេសនៅភូមិភាគបូព៌ា និងភូមិភាគនិរតី ក្រចេះ ព្រមទាំង-ការថ្លឹងថ្លែងឲ្យមានតុល្យការមួយភាគពាយ័ពនៅដីមានជីជាតិល្អចំនួនដែល ្យសម្លាប់។ ការ ។ មេដឹកនាំដទៃទៀតបានជ្រើសយកអំពើហិង្សាឡើងកើតបានសាធារណរដ្ឋខ្មែរ ដែលឋានៈខ្ពស់ៗនៃអតីតដោយមិនរើសមុខទៅលើនាយទាហាន និងអ្នករដ្ឋការសហករណ៍។ ប៉ុន្តែនៅតាម រដូវក្តៅប៉ុន្មានខែដំបូងនៃរបបនោះ បានបញ្ឈប់នៅក្នុងពេលក្នុងរយៈពេល ការសម្លាប់អ្នកដែលចោទថា ។ បន្តនៅតែ វិន័យសមូហភាពចោទថា មិនគោរពអ្នកដែលនិង ”មិនល្អសមាសភាព“ ឈ្លបភូមិវ័យក្មេងម្នាក់បានពន្យល់ថា ៖

> អ្នកដែលយើងបានរកឃើញនៅពេលយប់ថា បានកំពុងនិយាយអ្វីដែលមិនល្អ យើងត្រូវអប់រំ មានន័យថាអ្នកទាំងនោះត្រូវធ្វើការងារធ្ងន់ជាងអ្នកដទៃបើអ្នកទាំងនោះនៅតែ។ ប្រសិន ប ្រព្រឹត្តកំហុសទៀត គេនឹងត្រូវសម្លាប់ដោយដំបង ឬពូថៅកប់ ត្រូវ។ ក្រោយមក ពួកគេ ...ហើយមានតែប៉ុណ្ណឹង។ កុមារក៏ត្រូវបានសម្លាប់ដែរ ប្រសិនបើពួកគេបានប្រព្រឹត្តកំហុស


Translated: [00396488-00396489]; [00396491]; [00396530]; [00396497-00396499]; [00396713-00396714]; [00396501-00396502]; [00396503-00396504]; [00396508-00396509]; [00396425]; [00396536]; [00396513]; [00396514]; [00396577-00396578]; [00396721]; [00396514-00396516]; [00396552-00396553]; [00396528]; [00396529]; [00396530]; [00396554]; [00396555]; [00396556]; [00396560]

ច្រើន ...។ ខ្ញុំយល់ស្របជាមួយនឹងការសម្លាប់ទាំងនោះ ...។ អ្នកដែលប្រព្រឹត្តកំហុសត្រូវតែទទួលខុសត្រូវចំពោះកំហុសពួកគេ។

ដោយសារការសម្លាប់បានធ្វើឡើងនៅពេលយប់ ហើយជាសម្ងាត់ វាបានធ្វើឲ្យមានទម្លាប់មួយមិនល្អ ៖ អង្គ“ ”ការសម្លាប់ ប៉ុន្តែមិនពន្យល់ហេតុផល។ ប៉ុន្តែវិធីសាស្ត្រនេះក៏បាននាំមកដែរនូវការខាតបង់មួយ ៖ រាល់មនុស្សដែលបានស្លាប់ មានន័យថា បាត់មនុស្សម្នាក់សម្រាប់ធ្វើការ។

**ជើងទំព័រ ៖**

321 ***មេដឹកនាំទទួលស្គាល់*** ...ម្នាក់ពីរកំប៉ុងទឹកដោះគោក្នុងមួយថ្ងៃរបបអង្ករគួរតែបាន“ ***ក្នុងមួយថ្ងៃ ៖...*** ”ការងារនឹងត្រូវចុះថយកម្លាំងខូចសុខភាពប្រជាជន ហើយបន្ទាប់មកបើខ្វះខាតនឹងនាំឲ្យប្រសិន )កំណត់ហេតុប្រជុំគណៈអចិន្ត្រៃយ៍ បកក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៧៦ មជ្ឈមណ្ឌលឯកសារកម្ពុជា (។ សូមមើលផងដែរ ប៉ុល ពត *ផែនការបួនឆ្នាំ*-១១១ទំព័រ) ១២របបដែលកំណត់ (អាហារក្នុងចន្លោះពី ១ ម្នាក់ក្នុងកំប៉ុងទឹកដោះគោ ៣ ទៅ ៥.។ ដោយសារឯកសារប្រភេទនេះ ជាពិសេសគឺកំណត់ហេតុគណៈអចិន្ត្រៃយ៍ ដែលផ្សព្វផ្សាយទៅតែមនុស្សចំនួនតិចជាង១0នាក់ គឺមានលក្ខណៈកំណត់រឹតត្បិតខ្លាំង មិនដែលមានបំណងផ្សាយឲ្យបានទូលាយជាងនេះនោះ គេអាចនឹងសន្និដ្ឋានបានថា ទស្សនៈដែលប៉ុល បានលើកឡើងនោះ ប្រាកដជាអ្វីដែលគាត់ពិតជាប្រកាន់យកមែន “ ។ ***ថ្នាំដែលមានសារៈសំខាន់បំផុតនោះ ”ក្នុងចំណោមយើង ...៖*** *ទង់បដិវត្ត* ខែមិថុនា ឆ្នាំ១៩៧៦ ។ ប៉ុល ពត *ការពន្យល់ជាបឋម* ទំព័រ១២៧ ។ ***ថ្ងៃសម្រាកមួយថ្ងៃ ថ្ងៃ ៖១៥រហូតដល់សរុបហើយ ...***ប៉ុល ពត *ផែនការ៤ឆ្នាំ* , ទំព័រ ១១២ ។ សូមមើលផងដែរ គ្រីដល និង ប៊ុត ម៉ម *កម្ទេច* ទំព័រ ១៥៨ ។ ពិន យ៉ាថៃ *ត្រូវតែរស់* ទំព័រ៨៩ ។ ស្ទួតហ្វក្ស *បដិវត្តដែលពោរពេញដោយមនុស្សឃាត* ទំព័រ៤៥ ។ ហាំង ងោ *ដំណើរដ៏វែងឆ្ងាយ* ទំព័រ ២៧៤ ។ និង ឃៀនិន *ការរៀបចំឡើងវិញនៅជនបទ* ទំព័រ៦៥ ។ “***មិនមានគ្រប់គ្រាន់ទេ”*** ៖ ប៉ុល ពត *ការពន្យល់ជាបឋម* ទំព័រ១៥៨ ។

322 ***អ្នកដែលយើងបានរកឃើញ ៖*** បានដកស្រង់នៅក្នុងម៉ាទីន *រងការខ្ទេចខ្ទាំ* ទំព័រ១៦៧-៨ ។ ***ពាក្យស្លោក*** ឡូកាដ៍ *កូនសៀវភៅក្រហម* ទំព័រ១៧៥ ។ កេង វ៉ាន់សាក់ បានអះអាងថា ឃ្លានេះមានបំណងពន្យល់

ឲ្យយល់តាមន័យត្រង់តែម្តង-"មនុស្សត្រូវបានបន្ទាបមកត្រឹមជាកម្មវត្ថុនៃការចំណេញ និងខាត" (បានដកស្រង់នៅក្នុងបីសេត *ត្រីកោណ* ទំព័រ ៩៤) ។

បកប្រែ [ERN 00396530]

[ERN 00396554]

នៅក្នុងជួរថ្នាក់ដឹកនាំកំពូល អ្វីៗក៏អាចមានដែរ ។ ជួន ម៉ុម បានរំឭកឡើងវិញនូវអ្វីដែលតែងតែមាននៅទីបញ្ជាការរបស់វ៉ន វ៉េត "នៅលើតុតែងតែមានផ្លែឈើស្រស់មួយកន្ត្រក ។ ខ្ញុំមិនដែលបានហូបល្អជាងនេះទេក្នុងមួយជីវិតរបស់ខ្ញុំ ។" នៅពេលដែលភរិយារបស់កងការពារម្នាក់មានផ្ទៃពោះ យុន យ៉ាត ដែលជាប្រពន្ធរបស់សុន សេន បានផ្ញើសេរ៉ុំជាកាដូមកឲ្យ ។ សីហនុបានចាំបានថា នៅទីស្នាក់ការគណៈមជ្ឈិម ទ្រង់បានទទួលនូវ "នំប៊ីស្គិតជប៉ុន ប៊ឺរអូស្ត្រាលី នំប៉័ងបាហ្គែតរបស់បារាំង ពងទា... និងក្តាមខ្មែរដែលមានខ្លាញ់រសជាតិឆ្ងាញ់" ព្រមទាំងមានផ្លែឈើតំបន់ត្រូពិចដែលបានដាំនៅមូលដ្ឋានតែម្តង "ក្រូចពោធិ៍សាត់ ធូរ៉េនកំពត សាវម៉ាវ និងម្នាស់" ។ នៅពេលដែលអៀង សារី ត្រឡប់មកពីដំណើរទៅអង្គការសហប្រជាជាតិ គាត់បានយកមកជាមួយគាត់នូវអាហារបំប៉ន ថ្លើមទា និងហ្វ្រូម៉ាស្វីស មួយកន្ត្រកមកជាមួយផង ។ មេដឹកនាំទាំងអស់កាន់តែធាត់ជាងមុន ។ រូបថត ដែលជាបច្ចុប្បន្នភាពនៅពេលនោះបង្ហាញថា ប៉ុល និង នួន ជា មើលទៅធាត់កំប៉ោង ។ ខៀវ សំផន ឡើងទម្ងន់ ហើយមានសម្បុរឡើងក្រហម ដូចជាសុខភាពមិនល្អ ។

ក្នុងពេលជាមួយគ្នានោះនៅតាមជនបទវិញ ឧបករណ៍មនោគមន៍វិជ្ជាកាន់តែរឹតបន្តឹងខ្លាំងឡើងៗ ។

ការដើររកអាហារមកបរិភោគ ដែលបានជួយអ្នកភូមិជាច្រើនឲ្យផុតពីការអត់ឃ្លាននៅក្នុងឆ្នាំដំបូងនៃរបបខ្មែរក្រហម ឥឡូវនេះត្រូវបានថ្កោលទោសថាជាការប្រព្រឹត្តនូវបុគ្គលនិយម ហើយត្រូវហាមឃាត់ដោយឈរលើមូលហេតុថា វានឹងបណ្តាលឲ្យអ្នកខ្លះមានជាងអ្នកខ្លះទៀត ។ ឈរលើហេតុផលដូចគ្នានេះ កម្មាភិបាលមូលដ្ឋាន បានបដិសេធមិនឲ្យអ្នកភូមិឲ្យរកត្រី ឬសម្លាប់ស្វា និងជ្រូកព្រៃ ដែលចូលមកក្នុងចម្ការ ។

ការបេះដូងដោយគ្មានការអនុញ្ញាត គឺជាអំពើប្រឆាំងបដិវត្ត ។ អៀង សារី បានបណ្តេញចេញនូវកម្មាភិបាលក្រសួងការបរទេសម្នាក់ដោយមូលហេតុនេះ ។ ផ្លែឈើដែលធ្លាក់មកដី គួរតែទុកឲ្យស្អុយរលួយ មិនត្រូវ



Translated: [00396488-00396489]; [00396491]; [00396530]; [00396497-00396499]; [00396713-00396714]; [00396501-00396502]; [00396503-00396504]; [00396508-00396509]; [00396425]; [00396536]; [00396513]; [00396514]; [00396577-00396578]; [00396721]; [00396514-00396516]; [00396552-00396553]; [00396528]; [00396529]; [00396530]; [00396554]; [00396555]; [00396556]; [00396560]

រើសមកប្រើជាបុគ្គលឡើយ ។ "វាជាកម្មសិទ្ធិរបស់អង្គការ" បណ្ដាឃោធាទាំងឡាយនឹងនិយាយដូច្នេះ ពេលដែលគេហាមមិនឲ្យអ្នកណាប៉ះវា ។

**មិនមានជើងទំព័រ**

បកប្រែ [ERN 00396554]

[ERN 00396555]

ចាប់ពីរដូវក្ដៅឆ្នាំ១៩៧៦តទៅ កុមារអាយុលើសពី៧ឆ្នាំបានបំបែកចេញពីឪពុកម្ដាយរបស់ពួកគេ ហើយទៅរស់នៅប្រមូលផ្ដុំដោយឡែកជាមួយនឹងគ្រូៗខ្មែរក្រហម ដែលបង្រៀនកុមារទាំងនោះអំពីចម្រៀងបដិវត្ត ហើយចាត់តាំងឲ្យកុមារទាំងនោះធ្វើការស្រាលៗនៅតាមវាលស្រែ-ក្នុងលក្ខណៈមួយដូចយ៉ាងច្រើនទៅនឹងកុមារកម្ពុជាប៉ុន្មានជំនាន់មុន ដែលបានទៅរស់នៅបួសលោកនេននៅតាមវត្ត ។ ឪពុកម្ដាយមិនអនុញ្ញាតឲ្យដាក់ពិន័យទៅលើកូនៗរបស់ខ្លួនឡើយ ។ សិទ្ធិដាក់ពិន័យនេះផងដែរជាកម្មសិទ្ធិរបស់អង្គការក្នុងនាមសមូហភាព មិនមែនបុគ្គលឡើយ ។

**មិនមានជើងទំព័រ**

បកប្រែ [ERN 00396555]

[ERN 00396555-00396556]

នៅថ្នាក់លើបន្តបន្ទាប់មក តួនាទីទាំងឡាយរបស់កម្មាភិបាលនៅក្នុងឋានានុក្រម បានឆ្លុះបញ្ចាំងតាមរយៈគុណភាពនៃក្រមាដែលកម្មាភិបាលទាំងនោះពាក់ ជាស្ទូត្រ ឬអំបោះឆ្នូតចម្រុះពណ៌ ឬចំនួនប៊ិកដែលដាក់នៅហោប៉ៅខាងលើរបស់គេ ។ លេខាឃុំមានកង់ប្រើ លេខាស្រុកមានម៉ូតូ ហើយលេខាតំបន់ និងថ្នាក់លើមានឡាន ។



Translated: [00396488-00396489]; [00396491]; [00396530]; [00396497-00396499]; [00396713-00396714]; [00396501-00396502]; [00396503-00396504]; [00396508-00396509]; [00396425]; [00396536]; [00396513]; [00396514]; [00396577-00396578]; [00396721]; [00396514-00396516]; [00396552-00396553]; [00396528]; [00396529]; [00396530]; [00396554]; [00396555]; [00396556]; [00396560]

តម្រូវការផ្សេងៗទៀតរបស់មនុស្សក៏មិនមានអ្វីជារបស់ខ្លួនឯងផ្ទាល់ ហើយត្រូវស្អាតស្អំទៅតាមមនោគមន៍វិជ្ជាដែលខ្មែរក្រហមបានកំណត់ ។ ក្នុងកាលៈទេសៈមួយដែលប្ដី និងប្រពន្ធ រំពឹងថា មិនអាចបង្ហាញជាសាធារណៈនូវសេចក្ដីស្រឡាញ់របស់ខ្លួនទៅវិញទៅមក ហើយសូម្បីតែឈរជិតគ្នាក៏មិនបាននោះ កម្មាភិបាលមូលដ្ឋានល្បួងនារីក្មេងៗស្អាតៗយកទៅរួមភេទ ហើយក្រោយមកសម្លាប់នារីទាំងនោះដោយមូលហេតុថាខុសសីលធម៌ ។ នារីម្នាក់បានចោទប្រកាន់បកទៅលើអ្នកដែលចោទកំហុសមកលើនាងវិញ ដោយអះអាងថា នាងក៏បានរួមភេទរួចទៅហើយផងដែរ ជាមួយនឹងអ្នកមានអំណាចនៅក្នុងភូមិពីរនាក់ផ្សេងទៀត ។ នាងត្រូវបានសម្លាប់ ប៉ុន្ដែពួកគេក៏ត្រូវបានសម្លាប់ដែរ ។ ប្រជាជនដែលបានជម្លៀសមកជាមួយនាងបានចាត់ទុកនាងថាជាវីរនារី ។ ដូចនៅក្នុងប្រទេសចិន និងកូរ៉េខាងជើង ក្រុមសិល្បៈបដិវត្ដដែលសម្ដែងនៅក្នុងការឃោសនានានា គឺជាប្រភពនារីពេញវ័យដែលពួកគេយកមករៀបការ ។

នារីទាំងនេះបានទទួលនូវរបបអាហារពិសេស ហើយនៅក្នុងប្រទេសមួយដែលមិនមានការលំហែនៅក្នុងទម្រង់ណាមួយផ្សេងទាល់តែសោះនោះ នារីទាំងនេះគឺមានន័យស្មើនឹងតារាភាពយន្ដ ។ ទីវ អុល អនុរដ្ឋមន្ដ្រីក្រសួងព័ត៌មានវ័យក្មេង និងសង្ហារ បានធ្លាក់ពីបុណ្យស័ក្ដិបន្ទាប់ពីប្រធានរបស់គាត់ហ៊ូ នឹម បានដឹងថា គាត់ “បានល្បួកស្ទាបដោះ និងយោនី” របស់អ្នកសម្ដែងសិល្បៈរបស់ក្រសួង ។ នួន ជា ដែលបានគេមកសុំយោបល់នោះបានឲ្យយោបល់ថា មិនបាច់ចាត់វិធានការអ្វីទេ ។ ប៉ុន្ដែនឹម នៅតែទទូចដោយលើកឡើងថា ហេតុការណ៍របៀបនេះបានដឹងសុសសាយច្រើនពេកហើយ មិនអាចគ្រាន់តែទុកចោលនោះឡើយ ។ ជួន ម៉ុម នៅចាំបានថា ប្រធានមន្ទីរពេទ្យដែលជានារីម្នាក់ត្រូវបានសម្លាប់ដោយមូលហេតុថា នាងបានចាត់ចែងឲ្យនារីពេទ្យទៅបម្រើការនៅកន្លែងបម្រើផ្លូវភេទសម្ងាត់មួយសម្រាប់តែកម្មាភិបាលតែខ្មែរក្រហម ។

អំពើរំលោភបំពានបែបនោះកើតឡើងនៅគ្រប់ប្រទេសទាំងអស់ ដែលមានប្រព័ន្ធដឹកនាំបែបផ្ដាច់ការដែលបុព្វសិទ្ធិនៅក្នុងប្រព័ន្ធនោះអាស្រ័យទៅលើអំណាច ហើយមិនមានការពិនិត្យ និងតុល្យការ ដើម្បីធានាឲ្យមានយុត្ដិធម៌សង្គមអប្បរិមាណាមួយឡើយ ។ នេះមិនមែនជាលក្ខណៈសម្គាល់របស់កុម្មុយនីស្ដនិយមទេ ប៉ុន្ដែជារបស់លទ្ធិផ្ដាច់ការ ទោះជារបបនយោបាយពណ៌អ្វីក៏ដោយ ។


Translated: [00396488-00396489]; [00396491]; [00396530]; [00396497-00396499]; [00396713-00396714]; [00396501-00396502]; [00396503-00396504]; [00396508-00396509]; [00396425]; [00396536]; [00396513]; [00396514]; [00396577-00396578]; [00396721]; [00396514-00396516]; [00396552-00396553]; [00396528]; [00396529]; [00396530]; [00396554]; [00396555]; [00396556]; [00396560]

ប៉ុន្តែនៅក្នុងកម្ពុជាប្រជាធិបតេយ្យភាពផ្ទុយគ្នាស្រឡះបានមើលឃើញយ៉ាងជាក់ស្តែង ដែលមនុស្សទាំងឡាយអាចយកជាគំរូធ្វើតាមបាន ។ ក្រុមមេដឹកនាំជាន់ខ្ពស់ដែលគេបានលើកបន្តុបមួយចំនួនតូចនោះមិនត្រឹមតែកំណត់ទៅលើជោគវាសនានៃប្រជាជាតិនៃពួកទាសករប៉ុណ្ណោះទេ ។ ប៉ុន្តែរបបដែលពួកថ្នាក់ដឹកនាំទាំងនោះបានបង្កើតឡើង បានធ្វើឱ្យភាពបរិសុទ្ធខាងមនោគមន៍វិជ្ជា ការចចេសរឹងរូស និងការលះបង់ ការបោះបង់សម្ភារនិយម ការដាក់សម្ពាធលើខ្លួនឯង មូលដ្ឋានគ្រឹះនៃគោលនយោបាយជាតិ បានមានតម្លៃលើសលុបទៅលើការពិចារណាអ្វីផ្សេងៗទៀតទាំងអស់ ។

ការហាមឃាត់មិនឱ្យដើររកអាហារហូប មិនមែនជាការនិយាយបំភ្លើសដោយកម្មាភិបាលមូលដ្ឋានដែលមិនមានការអប់រំនោះទេ ។ វាបានអនុម័តដោយថ្នាក់ដឹកនាំជាតិនៅឯភ្នំពេញ ។ នៅពេលដែលត្រូវជ្រើសរើសរវាងថាតើត្រូវអនុញ្ញាតឱ្យប្រជាជនដែលអត់ឃ្លានដើររកអ្វីហូបដោយខ្លួនឯង ឬត្រូវគោរពលទ្ធិសមភាពនិយមដាច់ខាត (នៅក្នុងដំណាក់កាលដែលអាហារកំពុងតែក្លាយទៅជាសំរាម) ឬយ៉ាងណានោះ របបនោះបានជ្រើសយកលទ្ធិសមភាពនិយម ។ គេអាចលើកឡើងថា នេះអាចជាការខ្វះចន្លោះមួយដែលថ្នាក់ដឹកនាំមិនដែលបានប្រមើលមើលឃើញថា ការហាមឃាត់ទាំងនេះបានអនុវត្តនៅក្នុងស្រុកដែលមានការអត់ឃ្លាននោះឡើយ ។ ហើយជាការពិត ប៉ុល បាននិយាយជារើយៗអំពីតម្រូវការដែលត្រូវលើកកម្ពស់កម្រិតជីវភាពរស់នៅ ។ នៅខែសីហា ឆ្នាំ១៩៧៦ គាត់បានអំពាវនាវឱ្យថ្នាក់ដឹកនាំតំបន់ជ្រើសរើសចុងភៅល្អៗ “ដើម្បីកុំឱ្យមានអ្នកណាទិតៀនពីសញ្ញាណនៃសមូហភាពនិយម ហើយនិយាយថា ម្ហូបអាហារ... ដែលធ្វើជាសមូហភាពនោះមានរសជាតិមិនល្អ... ប្រសិនបើចុងភៅធ្វើអាហារមានរសជាតិឆ្ងាញ់ ក្រពះប្រជាជននឹងពេញឆ្អែត ។” ប៉ុន្តែជាក់ស្តែងកង្វល់របស់គាត់គឺមិនមែនថា ប្រសិនបើសមូហភាពបរាជ័យ ប្រជាជនមិនពេញចិត្តនោះឡើយ ផ្ទុយមកវិញថា បុគ្គលនិយមអាចនឹងកើតឡើងជាថ្មីម្តងទៀត ។ គាត់ប្រាកដជាបានដឹងថា នៅតំបន់ខ្លះមានគ្រោះទុរភិក្សយ៉ាងខ្លាំង ។ របាយការណ៍ពិស្តារមកពីគណៈភាគបានមកដល់លើតុរបស់គាត់ជារៀងរាល់សប្តាហ៍-ប៉ុន្តែមានតែគាត់មិនចង់គិតអំពីវា ឬក៏គាត់បានចាត់ទុកថាវាជារឿងមិនសំខាន់ ។

នេះមិនមែនជាករណីលើកលែងមួយនោះទេ៖ ប៉ុន្តែវាគឺជាច្បាប់វិន័យ ។ នៅពេលណាដែលគោលការណ៍មនោគមន៍វិជ្ជា និងផលប្រយោជន៍ជាក់ស្តែងដើរបញ្ច្រាសគ្នានោះ គោលការណ៍នឹងត្រូវតែប្រកាន់យកឈ្នះដើរទៅមុខ ដោយមិនគិតពីការខូចខាតខាងសម្ភារៈឡើយ ។



Translated: [00396488-00396489]; [00396491]; [00396530]; [00396497-00396499]; [00396713-00396714]; [00396501-00396502]; [00396503-00396504]; [00396508-00396509]; [00396425]; [00396536]; [00396513]; [00396514]; [00396577-00396578]; [00396721]; [00396514-00396516]; [00396552-00396553]; [00396528]; [00396529]; [00396530]; [00396554]; [00396555]; [00396556]; [00396560]

**ជើងទំព័រ ៖**

348 ***របាយការណ៍ពិស្តារ ៖*** “របាយការណ៍នៃមហាសន្និបាតភូមិភាគបូព៌ា ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៧៧” ឯកសារ 32 (N442)/T8294 វ៉ា ដែលបាននិយាយអំពីគ្រោះថ្នាក់ “នៃប្រជាជនកំពុងអត់ឃ្លាន និងរងទុក្ខវេទនា ហើយបាត់បង់ការជឿជាក់លើបក្ស ។” សូមមើលផងដែរនូវទូរលេខជាប្រចាំ ស្តីអំពីសភាពការណ៍សេដ្ឋកិច្ចនៅក្នុងតំបន់នានានៅក្នុង “ឯកសារទំនាក់ទំនងរបស់ខ្មែរក្រហម” មជ្ឈមណ្ឌលឯកសារកម្ពុជា ។ គិតមកត្រឹមពាក់កណ្តាលឆ្នាំ១៩៧៦ ការផ្គត់ផ្គង់អាហារមានសភាពធ្លាក់ដុនដាបសូម្បីតែនៅក្នុងក្រសួងការបរទេសនៅភ្នំពេញក៏ដោយ ។ នៅចុងឆ្នាំនោះ ឡូរ៉ង់ ពិច និងបុគ្គលិកផ្សេងៗទៀតរបស់ក្រសួង បានកើតដំបៅលើខ្លួនដោយសារតែខ្វះជីវជាតិ (ពិច *នៅឯជើងមេឃ* ទំព័រ៦៧-៨, ៧៨ និង៨៤) ។

បកប្រែ [ERN 00396555-56]

[ERN 00396560]

ឫស្សគល់នៃបញ្ហា គឺថាសហករណ៍ទាំងឡាយផលិតបានតិចជាងអ្វីដែលរបបនោះ និងអ្នកសង្កេតការណ៍ខាងក្រៅភាគច្រើនបានជឿជាក់ ។ មូលហេតុមួយផ្នែកគឺដោយសារយុវជន និងនារីដែលមានកម្លាំងខ្លាំងបានចំណាយពេលយ៉ាងច្រើននៅក្នុងមួយឆ្នាំៗនៅក្នុងកងចល័តកសាងប្រព័ន្ធប្រឡាយមិនបានមកថែទាំស្រែស្រូវរបស់ពួកគេឡើយ ហើយជាលទ្ធផល ទោះបីជាប្រជាជនជនបទទាំងមូលបានកើនឡើង (ដោយមានការបន្ថែមមកនូវប្រជាជនដែលជម្លៀសមកពីទីក្រុង) កម្លាំងពលកម្មមានប្រសិទ្ធភាពបានធ្លាក់ចុះរួចទៅហើយ ។ ប្រទេសចិនបានជួបប្រទះនូវបញ្ហាស្រដៀងគ្នានេះដែរ ហើយបានជួបនូវគ្រោះទុរភិក្សកាន់តែធ្ងន់ធ្ងរជាងនេះទៅទៀតកាលពីចុងទសវត្សរ៍១៩៥០ នៅពេលដែលប្រជាជនមួយផ្នែកបានបង្វែរឲ្យទៅធ្វើការងារឡដែកនៅខាងក្រោយផ្ទះទៅវិញ ។ ប៉ុន្តែបញ្ហាសំខាន់ជាងនេះទៅទៀតគឺការខ្វះការលើកទឹកចិត្ត ។ សូម្បីតែនៅក្រោមសម្ពាធធ្ងន់ធ្ងរក៏ដោយ ទាសករធ្វើការមានប្រសិទ្ធភាពតិចជាងមនុស្សមានសេរីភាព ។ ជាថ្មីម្តងទៀត បទពិសោធន៍របស់ប្រទេសចិន គឺជាគន្លឹះ ។ កាលពី នៅឆ្នាំ១៩៨០ តេង ស៊ីវពីង បានដាក់ឲ្យដំណើរការនូវអ្វីដែលហៅថា “របបទទួលខុសត្រូវតាមផ្ទះ” ដោយអនុញ្ញាតឲ្យគ្រួសារកសិករខ្នាតតូចៗទទួលនូវការទទួលខុសត្រូវ និងទទួលផលនៃ



Translated: [00396488-00396489]; [00396491]; [00396530]; [00396497-00396499]; [00396713-00396714]; [00396501-00396502]; [00396503-00396504]; [00396508-00396509]; [00396425]; [00396536]; [00396513]; [00396514]; [00396577-00396578]; [00396721]; [00396514-00396516]; [00396552-00396553]; [00396528]; [00396529]; [00396530]; [00396554]; [00396555]; [00396556]; [00396560]

ការបង្កបង្កើនផលរបស់ខ្លួនផ្ទាល់ ជាជាងការធ្វើការជាសមូហភាពនោះ ផលដំណាំនៅក្នុងប្រទេសចិន បានទទួលកើនឡើង៤០% ។ នៅប្រទេសកម្ពុជា កសិករបានទទួលនូវសម័យអន្តរកាលបញ្ច្រាសទិសមួយចេញពីសហគ្រាសសេរីទាំងស្រុង ទៅកាន់របបមួយដែលគ្មានការលើកទឹកចិត្តអ្វីទាំងអស់ ។ មេកងត្រួតពិនិត្យអាចនឹងអនុវត្តបាននូវកូតាប្រចាំថ្ងៃក្នុងការសែងដី ប៉ុន្តែមិនអាចត្រួតពិនិត្យបាននូវគុណភាពនៃការស្ទូង ការប្រើប្រាស់ជីជម្រៅនៃការភ្ជួររាស់ដី ឬកិច្ចការរាប់ពាន់ជំពូកទៀត ដែលកំណត់បាននូវទិន្នផលចុងក្រោយ ។ នៅក្នុងប៉ុន្មានឆ្នាំនៃរបបខ្មែរក្រហម ប្រហែលជារវាង ១/៣ ទៅដល់ពាក់កណ្តាលនៃប្រជាជនទាំងមូលបានធ្លាក់ខ្លួនឈឺ អត់អាហារ ឬទាំងពីរមុខនេះ ហើយមិនស្ថិតនៅក្នុងសភាពដែលអាចធ្វើការធ្ងន់បាននោះឡើយ ។ ប្រជាជនផ្សេងៗទៀត ទោះជាមានលទ្ធភាពខាងផ្លូវកាយក៏ដោយ មានហេតុផលគ្រប់យ៉ាងតម្រូវឲ្យពួកគាត់ធ្វើត្រឹមតែបានអប្បបរមា គ្រាន់តែឲ្យអ្នកយាមរបស់គាត់ឲ្យគាត់រួចខ្លួនតែប៉ុណ្ណោះ ។


Translated: [00396488-00396489]; [00396491]; [00396530]; [00396497-00396499]; [00396713-00396714]; [00396501-00396502]; [00396503-00396504]; [00396508-00396509]; [00396425]; [00396536]; [00396513]; [00396514]; [00396577-00396578]; [00396721]; [00396514-00396516]; [00396552-00396553]; [00396528]; [00396529]; [00396530]; [00396554]; [00396555]; [00396556]; [00396560]